**BMI0161**

## សម្ភាសន៍ជាមួយឈ្មោះ ភាច រស់ ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ «កងភ្ជួរ»

## សព្វថ្ងៃរស់នៅភូមិស្រែះកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ហ៊ិន សុធានី

## ០១:០៣:៥៧

## ៣៨ទំព័រ

រស់ : ដេកមិនសូវបាន ណាអត់ឃ្លាន ណាមួយជម្ងឺ ណាមួយខ្លាចគេវ៉ៃចោល មិនបានទៅធ្វើការ ងារគេវ៉ៃចោល ។

ធានី : ចុះពូដឹងប្រវត្តិភូមិនឹង កាលពីមុនភូមិនឹងយ៉ាងម៉េច ម៉េចបានមានភូមិនឹងគេដាក់ឈ្មោះភូមិ ស្រែះ?

រស់ : ភូមិស្រែះនេះ តាមចាស់ៗពីដើមមិញ វាមានភ្នំស្រែះៗ ភ្នំសេះៗ ដល់យូរៗភ្នំ ស្រែះ តាម ចាស់ៗពីដើមគាត់ ។

ធានី : បានដាក់ភូមិនឹងនៅក្បែរភ្នំនឹង?

រស់ : បាទ! ហើយកើតជាភូមិស្រែះកើត ។

ធានី : ចុះវត្តនេះកសាងយូរនៅ?

រស់ : កសាងប្រហែល៥០ឆ្នាំហើយ ។

ធានី : ចឹងវត្តនឹងកសាងយូរហើយ?

រស់ : បាទ! យូរគ្រាន់ដែរ ។

ធានី : កាលសម័យខ្មែរក្រហមវត្តនឹងវ៉ៃចោលដែរអត់ទេ?

រស់ : សម័យខ្មែរក្រហម អត់ទាន់បានធ្វើវិហារធ្វើអីទេ ហើយកន្លែងសាលាកន្លែងវត្តលោក គេ យកអ្នកជម្ងឺ ទៅសម្រាកពេទ្យកន្លែងសន្តមកិច្ចគេនោះ ។

ធានី : ចឹងមានព្រះសង្ឃស្នាក់នៅដែរ?

រស់ : សម័យខ្មែរក្រហមនឹង?

ធានី : ចា៎!

រស់ : អត់មានទេ ។

ធានី ៖ កាលមុននឹង?

រស់ ៖ មុននឹងមាន សម័យ លន់ នល់ មាន ។

ធានី ៖ ដល់ពេលហើយយ៉ាងម៉េច បានអត់មានវិញ?

រស់ ៖ សម័យ លន់ នល់ ខ្ញុំនឹងហើយគេចាប់ដោះស្បង់ជីពរ ។

ធានី ៖ ពូអ្នកបួស?

រស់ ៖ បាទ! ខ្ញុំអ្នកបួស ។ កាលមុនខ្មែរក្រហមរំដោះបាន៧៥ ។ សម័យ៧៥ គេឲ្យលោកនេះមកធ្វើស្រែ ភ្ជួរស្រែអីតាមនេះ ហើយដាំដំឡូងដាំអី ។ ដល់មកពាក់កណ្ដាលខែវស្សា៧៥នោះគេមកបកស្បង់ជីពរនេះ ។

ធានី ៖ អ្នកណាគេអ្នកបក ពូចាំឈ្មោះគាត់?

រស់ ៖ ពួកនេះ សនៗនោះដឹងស្រុកកំណើតកើតទីនៅកន្លែងណាទេ ប៉ុន្តែគេគ្រប់គ្រងនៅកន្លែងឃុំនេះ ។ មុននឹងគេជម្លៀកខ្ញុំបួសមក វៃចោលស្រែកដូចជ្រូក នៅម៉ាដួរខាងត្បូងភូមិ ។ ហើយវាលខាងត្បូងវត្តនេះ ក្លាយជាវាលពិឃាតមនុស្ស គេវៃចោលរហូតដល់កូនជិទុកយៀម ឈ្មោះនាង ម៉ក់ ស៊ី គ្នាមកពីបោកវល្លិ៍ បោចស្មៅពីស្រែក៏មកដល់បោះកូនទៅលើកយកជិពុះទង់ពីក្រោម កូនងាំ កាប់ពេញណាគេ ។

ធានី ៖ កូនអ្នកណាគេ?

រស់ ៖ កូនជិទុកយៀម ។

ធានី ៖ ឈ្មោះអីគេ?

រស់ ៖ ម៉ក់ ស៊ី វៃចោលទាំងកូនគេបុក ឲ្យជាប់ខ្សែទាហាន ខ្សែអ្នកតូច អ្នកធំ គេវៃចោលទាំងអស់ ។

ធានី ៖ ចឹងសម្លាប់នៅវាលមុខវត្តនឹង?

រស់ ៖ ទេ!សម្លាប់នៅស្រះ មាត់វាលខាងត្បូងភូមិ ហើយម៉ាដួរដើម... គេចាប់ពីណាពីណែបាញ់បានគេចងដើងចងដៃសែងយកទៅកប់តាមម៉ាដួរខាងវាលខាងត្បូង ។

ធានី ៖ ត្បូងភូមិ?

រស់ ៖ បាទ!

ធានី ៖ កន្លែងនឹងកន្លែងគេកប់មនុស្សច្រើនដែរ?

រស់ ៖ បាទ! ច្រើនចង់រាប់រយនាក់សម័យនោះ ។

ធានី ៖ ប៉ុន្មានទៅ?

រស់ ៖ អូ! ច្រើនដែរ អាកប់តាមដើមត្បូងភូមិនោះក៏កប់ តាមគៀនៗដើមភ្នំកប់ច្រើនៗ

ធានី ៖ មានអ្នកផ្សេងមកកស់?

រស់ ៖ អត់ទេ អត់មានមកកាស់ទេ ព្រោះសម្លាប់នោះ សម្លាប់ចោលទាំងពូជតែម្ដង ទាំងកូនទាំងចៅ ទាំងប្ដីប្រពន្ធ សម្លាប់ចោលទាំងអស់ៗ ម៉ាពូជៗដូចថាខ្មែរមេឃុំ គេសម្លាប់ម៉ាឃុំៗ

ធានី ៖ ខ្មែរមេឃុំ?

រស់ ៖ ហ្នឹងហើយ ប៉ុ យឿងនឹង ជំទុកមេឃុំ គេហៅជំទុកយឿម គាត់ធ្វើឃុំពីដើមៗ

ធានី ៖ ចឹងគាត់យកបងប្អូនគាត់ប៉ុន្មាននាក់ទៅ ដែលយកទៅសម្លាប់ខាងត្បូងឃុំ?

រស់ ៖ អូ! សម្លាប់ នេះខ្លះ ដឹងថាសម្លាប់ខាងណាខាងស្រែះលិច ខាងអីណាទៀតវាច្រើន ដឹងម៉ាខ្មែរស្រឡាយដឹងថាស្រាវជ្រាវៗថាខ្មែរទាហាន ខ្មែរភូមិខ្មែរស្មី គឺសម្លាប់ចោលទាំងអស់ៗ

ធានី ៖ ប៉ុន្តែជាទូទៅ ម៉េចបានគេយកវាលខាងត្បូងភូមិវត្តយើងធ្វើចឹង?

រស់ ៖ ទេ! អាខាងត្បូងភូមិនេះ គេម្យ៉ាងគេវៃឲ្យឃើញថាគំរូប្រជាជននឹងឲ្យឃើញជាក់ស្ដែង គេវៃ ចោលមែន ឬមិនមែន កុំឲ្យដូចថាប្រើប្រជាជនទៅវាយ៉ាប់អីនេះនោះ វាធ្វើគំរូទៅដើម្បី ប្រើប្រជាជនឲ្យធ្វើអីៗឲ្យខ្លាចៗ

ធានី ៖ ពូឃើញទាំងអស់គ្នា ឬលួចមើលបានយើងដឹង?

រស់ ៖ ខ្ញុំមើលពីវត្តទៅ ខ្ញុំបួសៗ

ធានី ៖ កាលនឹងពេលពូនៅបួសទេ អត់ទាន់ផ្សឹកទេ?

រស់ ៖ បាទ! ផ្សឹកទេ នៅបានម៉ាវស្សា បានគេចាប់ដកស្បង់ជីពរ ៤៨អង្គៗ ពេលនោះខ្ញុំសុំដែរ ដូចជាបងថ្លៃខ្ញុំ គាត់អាចារ្យបាលី ហើយតាភ្លើតនោះខាងអនុគុណ គាត់សុំថាឥឡូវសុំនៅចុះ ឲ្យពួកនេះក៏គេសឹកទៅៗ គេថានៅៗបាន គេនិយាយចេះ ប៉ុនប្រជាជនគេមិនឲ្យបៀតវត្តទេ ហើយឯងដោះស្រាយម៉េចដោះទៅ គោក្របីគេមិនឲ្យ ស្រែភ្លឺគេមិនឲ្យៗ ហើយឲ្យឯងទៅ លើកទំនប់កំប៉ោរទៀត ហើយមិនឲ្យប្រជាជនមិនឲ្យនៅជិតបៀតវត្ត ហើយអ្នកណានៅបាន បើស្ដីមិនឲ្យៗៗ

ធានី ៖ ហើយ សន នេះជាស្អីគេ ជាប្រធានភូមិ ប្រធានឃុំ?

រស់ ៖ សន នោះ អឺ!ជុំតាក្រក់នៅនោះ ប៉ុនតាក្រក់នៅនោះឯងទៅ តាសន ជាអ្នកដើមកាប់សម្លាប់ៗ

ធានី ៖ តាក្រក់នៅខាងណា?

រស់ ៖ តាក្រក់គាត់មេឃុំដែរ ប៉ុនមិនដឹងស្រុកកំណើតនៅណាទេៗ

ធានី : គាត់មេឃុំអីគេ?

រស់ : មេឃុំដែលសម័យខ្មែរក្រហម រំដោះបានហើយនឹង ។

ធានី : គាត់មេឃុំអីគេ ដូចយើងនៅនេះមានឃុំព្រះនេត្រព្រះ មានអីចឹង?

រស់ : បាទ! មេឃុំព្រះនេត្រព្រះ ។

ធានី : ចុះតាក្រក់នឹងជាស្អីគេ?

រស់ : តាក្រក់នោះគាត់មេឃុំ ។

ធានី : ចុះតាសន?

រស់ : តាសន គាត់នោះប្រហែលជាអនុភូមិនេះឯង ប៉ុនតាសននឹង គាត់អ្នកដើរវ៉ៃ ។

ធានី : សននឹង គាត់ជាអ្នកក្រោមតាក្រក់?

រស់ : បាទ! ក្រោម ។

ធានី : តែតាសន នឹងគាត់ជាអ្នកដើរវ៉ៃ?

រស់ : បាទ! សន នឹង ជាអ្នកវ៉ៃ អ្នកសាហាវ ។

ធានី : សព្វថ្ងៃគាត់នៅរស់ទេ?

រស់ : ទេ! សម័យ ដូចថាពួកនិរតីមក ក៏បាត់រូបរាងហើយពួកនោះ មិនដឹងថាគេសម្លាប់ចោល មិនដឹងថាអីទេ ពួកនោះ ។

ធានី : ចុះពូ ពេលដែលពូជាពូបួស គេឲ្យផ្សឹក១ហើយ យើងផ្សឹកតាមធម្មវិន័យរបស់ព្រះពុទ្ធសាសនាយើង?

រស់ : បាទ! ផ្សឹកនោះ រៀនសូត្រ ប្រោះព្រំ គ្មានឯងទេ ដូចថាលោកតាភ្លើន គាត់នៅគ្នាគាត់ អនុគុណ អានេះអាចារ្យបាលី នាំគ្នាផ្សឹក ស្រុះស្រួលគ្នាទៅ ។

ធានី : កាលនឹងពូចាំទេ ពូសឹកឆ្នាំប៉ុន្មាន?

រស់ : ខ្ញុំផ្សឹកឆ្នាំ៧៥ ។

ធានី : ៧៥ម៉ង?

រស់ : បាទ! ៧៥គេរំដោះ ហើយភ្ជួរស្រែបានម៉ាវស្សានឹង គេផ្សឹកអារួចម៉ាវស្សានឹង នៅក្នុងឆ្នាំ ៧៥នោះឯង ។

ធានី : ដល់ពេលផ្សឹកទៅ ពូទៅណា?

រស់ : ផ្សឹកទៅ គេឲ្យខ្ញុំកាប់អុស ឲ្យអ្នកធ្វើស្ករ ទៅអារដើមក្រសាំង ដើមក្រឡាញ់ពេញតែដើងភ្នំ ។

ធានី : ចឹងពូដើរព្រៃហូត?

រស់ : ទេ! មិនបានជាដើរព្រៃទេ គ្រាន់កាប់គៀនភូមិ កាប់អារដើមក្រសាំង ដើមក្រឡាញ់ធំៗទៅ ឲ្យគេអ្នកដុតធ្វើស្ករៗ ហើយដល់ក្រោយមក គេឲ្យខ្ញុំភ្ជួរស្រែ ឲ្យជុំចាស់ៗធ្វើស្រែទៅ ក៏ទៅ ដល់ធ្វើឯត្បូងនោះឯង បានថាមានទោសនោះ ក៏គេឲ្យរែកដី៥ថ្ងៃៗ មានទោសនោះចេះ ឈ្មោះតារឿងៗនោះ គាត់ភ្ជួរប្រធានភ្ជួរៗ ដល់តាក្រក់ទៅឃើញ គាត់ថា *«ហ៊ៅ!អាមកភ្ជួរ ណាឃើតយ៉ាវម្ល៉េះ យើងចេះផ្នែប្រឌិត»* ដល់នាំគ្នារាយការណ៍ *«ពុកអើយ! ចាវវាគិច ហើយដីកមកទម្រាំ៧០ ហើយដីករទេះមានតែ២ដីកពូជ»* ហើយដល់ដីកទៅ អាអ្នកភ្ជួរនោះ មិនទាន់បានបរទៅដល់ផង ឯនោះភ្ជួរអស់ទៀតៗ នៅបញ្ឈរគោចោល ដល់តាក្រក់ឃើញ ថា យើងចេះផ្នែប្រឌិតផង ឲ្យស្ទុះរឿងភ្ជួររឿងអីៗ ចុះបាវមិនមាន គិតធ្វើម៉េច មាន ចោះដីរវាងចាក់ ទម្រាំអ្នកដីកមកដល់យើងភ្ជួរនេះរួចហើយ កុំឲ្យស្ទុះភ្ជួរៗ ដល់ឃើញឯង ចាក់ស្រូវនឹងដីនឹង ថាឯងខ្លាំងៗ យកមនុស្សទៅរែកដីនោះ នៅប៉ោយសំរោង ៤ម៉ែត្រ គីប ហើយទំនប់នោះដីកចេះទេ ប៉ុនរែកនោះពីនេះទៅដើមចាន់រី(ចាន់គីរី) សឹងពីនេះទៅ ស្រះៗ ចុះដើរត្រង់ចេះដើរមិនរួច ដើរបញ្ចិតៗវាខ្ពស់ៗ ហើយពេលណារែកនោះឯង ក្រោមម៉ោង១២យប់ៗក្រោករែកដី នេះសួរប្រពន្ធខ្ញុំ គាត់ធ្វើចុងភៅៗ ១២យប់ អាមើលអីមិនឃើញក៏រែក ហើយបើថាអ្នកណាខ្វាក់មាន់ចេះ គេដីកអន្ទងឲ្យយើងដើរមើល បើថាដើរទៅខ្វាក់មែន ធ្លាក់អន្ទង បើថាមិនខ្វាក់ទេ អត់ធ្លាក់អន្ទងទេ ចាប់យកទៅវ៉ៃ ចោលៗ

ធានី : ចុះគេធ្វើចឹងអី?

រស់ : គេខ្លាចយើងឈឺសតិអារម្មណ៍ យើងពុតខ្ជិលៗ

ធានី : ចុះបើយើងឃើញ យើងដើរចូលអន្ទងទៅគេថាយើង?

រស់ : គេថាយើងខ្វាក់មែន បើយើងមិនខ្វាក់អន្ទងទេ ឈឺសតិអារម្មណ៍ មុខតែកុហកគេចេះចុះ គេយកទៅវ៉ៃចោលហើយៗ ហើយមិនគួរនិយាយទៀត ពេលដែលខ្ញុំរែកដី ប៉ុននារីនោះ មិនដឹងថាងាប់ហើយរស់ទេ អ្នកថ្មី កំពុងប្រជុំច្រើនចេះ មានទោសចូលចាក់ស្រូវ អង្គុយ កៀនចេះ ចុះចាស់ៗផងៗ អង្គុយកៀនផង ស្រាប់តែឈ្មោះតាជនៗ គាត់អនុភូមិដែរ គាត់ថា *«យកនារីនោះវ៉ៃចោល កណ្តាលជំនុំនៃសមូហភាពឃើញ ព្រោះនារីនេះវាឈឺចេះ ឈឺសតិអារម្មណ៍ចេះចុះ ពេទ្យទៅពិនិត្យមិនមានថាឈឺអី»* ពូថាហៅនារីអង្គុយបៀតខ្ញុំចឹង

ស្រាប់តែគ្នាវាដូចថាដុះៗនោមមិននោម គ្នាភ័យគ្នា ។ គាត់ថា "ឯណាទារី ឆាប់មកៗ" ដល់នេះលើកអស់ គេស្រែកថា អ្នកណាហ៊ានធានា ខ្ញុំគេសំឡុតខ្លាំងមែនទែន អត់ហ៊ានចេះឡើង ។ ខ្ញុំអោនខ្លាចគេឃើញ "ពុកអើយ! ទុកកសាងបានម្ដង" មកៗ អ្នកណាថាៗរកមើល ។ បានចាស់ៗថា ទាំងអស់គ្នា បានខ្ញុំរួចខ្លួន ។ នារីនោះក៏បានរស់ទៅ កុំអីពេលនោះគេវ៉ៃចោលពេលនោះ ពួកប្រជុំថ្ងៃនោះ ។ ហើយខ្ញុំនៅសម័យនោះ គ្រាន់គេវ៉ៃចោល២-៣ដង ។ នៅដំបូកស្នាយ តាសិននោះ គាត់អនុប្រធានភូមិ ចឹងខ្ញុំដឹកក្របីស៊ីចេះ តាសិនថា "វើយ! ចងក្របីទុកនោះសិនហើយ មកហូបបបរសិន" ខ្ញុំថា "មាឯងពិសារមុន ខ្ញុំខ្លាចក្របី ដាច់ស៊ីស្រូវ" "ទេ! យើងមើលឃើញតើចំងាយប្រហែលជា៥០-៦០ម៉ែត្រ" ។ ហើយក៏ខ្ញុំ ចងគំនួចយ៉ាងចំណាប់ ។ ចងទៅរួង ក្របីនោះស៊ីសំណាបទល់ប៉ុ សន នោះគេដើរមកដល់ ភ្លាម គេចាប់ក្របីដើរដឹក "ឯណាម្ចាស់ក្របីហៅមកនេះវ៉ៃចោលនេះតែម្ដង ពុកនៅនោះ សុំអង្វរគេ" ថាយ៉ាប់នោះយ៉ាប់ហើយ តែក្របីស៊ីស្រូវក៏ខ្លាំង ។

ធានី : អ្នកណាគេថារកចាប់ពូ លើកក្រោយ?

រស់ : ឈ្មោះ ស ។

ធានី : ឈ្មោះ ស នេះជាអ្នកណាគេ?

រស់ : ស នោះ គេថាគេមេបញ្ជាការ គេមើលការខុសត្រូវនេះដង ដែលវាស់វែងច្រើនណាស់ ហើយអានោះក៏វ៉ៃចោលក៏ច្រើន អា ស ប៉ុនតែវាឆាប់ហើយ ឆាប់សម័យនោះហើយ ។ ពួកនិរតីមក ក៏វ៉ៃវាចោល ។

ធានី : មើលការខុសត្រូវអីគេ ស នឹង?

រស់ : គេមេបញ្ជាការខាងទ័ពនោះ ប៉ុនគេឲ្យចុះជាប់មើលការខុសត្រូវតាមសហករណ៍តាមអី ។

ធានី : គាត់មកពីណាវិញ ស?

រស់ : មិនដឹងមកពីណាពីណែទេ ពួកខាងនោះឯង ។

ធានី : អ្នកស្រុកយើង?

រស់ : ទេ! មិនដឹងគេមកពីខាងណាទេ ពួកខាងមជ្ឈឹមក្រោយមកបាននិរតី ។

ធានី : បស្ចឹម?

រស់ : បាទ! បស្ចឹម ។

ធានី : បន្ទាប់មកទៀតបាននិរតី?

រស់ ៖ បាទ!

ធានី ៖ និរតី អ្នកណាគេ ពូចាំឈ្មោះ?

រស់ ៖ និរតី ពួកខាងនារីធំនេះ ដែលធ្វើប្រធានសហករណ៍នេះ យាយថែមដែលធ្វើមេឃុំនោះ ។ អឺ!ចៅហ្វាយស្រុក យាយថែមគាត់ចៅហ្វាយស្រុក ប៉ុនគាត់នៅខាងភ្នំលាភនោះ ។

ធានី ៖ ចឹងគាត់ឈ្មោះ នារីធំ ប្រធានសហករណ៍យើងទេ?

រស់ ៖ ប្រធានសហករណ៍នៅនេះ ។

ធានី ៖ ដល់ពេលយាយថែម?

រស់ ៖ យាយថែម ចៅហ្វាយស្រុក ប៉ុនគាត់ទៅនៅភ្នំលាភ ។

ធានី ៖ ចៅហ្វាយស្រុកអីគេ?

រស់ ៖ ចៅហ្វាយស្រុកព្រះនេត្រព្រះ ។

ធានី ៖ អានឹងគេហៅចៅហ្វាយស្រុក ឬចៅហ្វាយឃុំ?

រស់ ៖ ចៅហ្វាយស្រុកសម័យខ្មែរក្រហម ។

ធានី ៖ គាត់មុខងារ ជាចៅហ្វាយស្រុក ឬចៅហ្វាយឃុំ គណៈសង្កាត់ ឬគណៈឃុំ?

រស់ ៖ ទេ! ចៅហ្វាយស្រុកតែម្ដង កាន់គ្រប់ភូមិតែម្ដង ម៉ាស្រុកព្រះនេត្រព្រះនេះ នឹងឯង គាត់អ្នកមកគ្រប់គ្រង ចៅហ្វាយស្រុកនោះ ។

ធានី ៖ ហើយម៉េចដែរ ចឹងនៅពេលដែល សន នោះនៅទៀតអត់ ពេលដែល ស មក?

រស់ ៖ សន នោះបាត់រូបហើយ នៅពេលដែលពួកនិរតីមកក៏បាត់មិនដឹងថាទៅណាទៅណែ ។

ធានី ៖ ចឹង ស នឹងស្រី ប្រុស?

រស់ ៖ ស នោះ ស្អី ស ទេ ប្រុស ។

ធានី ៖ ចាំមើលពូ គាត់មានឈ្មោះ សន នឹងនៅគ្រប់គ្រងភូមិយើង?

រស់ ៖ មួយ សន មួយ ស ។

ធានី ៖ បន្ទាប់មក ស?

រស់ ៖ បាទ!

ធានី ៖ ស នឹង ពូថាមកពីបស្ចឹម?

រស់ ៖ បាទ!

ធានី ៖ ចង់សួរថា ម្នាក់ ស នឹងស្រី ឬប្រុស?

រស់ ៖ ប្រុស ។

ធានី ៖ ចង់សួរថា ពេលដែល ស មកដល់ សន នឹងបាត់ខ្លួនហើយ ឬនៅ?

រស់ ៖ និរតីមក បាត់ ។

ធានី ៖ កាលពេល ពូ ស នឹងនៅ អត់ទាន់បាត់ទេ?

រស់ ៖ អត់ទាន់ទេ និរតី មិនទាន់មក សន នោះនៅ ។

ធានី ៖ ចឹងកាលពេលនិរតីមកប៉ុន្មានទាក់ ក្រៅពិយាយថែម?

រស់ ៖ និរតីមកច្រើនណាស់ មកគ្រប់ភូមិ គ្រប់អីតែម្តង ។

ធានី ៖ យាយថែមនាំមក?

រស់ ៖ យាយថែមដឹង គេខាងនិរតី គាត់នាំនិរតីមកគ្រប់គ្រងតាមភូមិ គ្រប់គ្រងតាមស្រុក ។

ធានី ៖ ចឹងយាយថែមនាំមក គណៈឃុំរបស់ពូដូរទៅអ្នកណាវិញ?

រស់ ៖ ដូរដល់ពេលនោះ កាលនោះភូមិពួកនិរតីមកពីណាវាភ្លេចដែរ ។ បើថានៅក្នុងភូមិសហករណ៍នេះមាននារីធំ ។ នារតីមកនេះ តាក្រក់ តាចាមនេះ យាយថែមនេះឯងចាប់យកទៅដាក់នៅក្នុងផ្ទះ ។

ធានី ៖ តាក្រក់នឹង ចាប់យាយថែមវិញ?

រស់ ៖ យាយថែមចាប់តាក្រក់ ចាប់ពួកបស្ទីម ចាប់យកទៅដាក់លើផ្ទះបាន មានអីដង្កាប់ម៉ូតូចាប់មួលសាច់ មិនដឹងទេ ។ មួលសាច់ព្រុតែមាត់ស្រែកឡូឡា ។

ធានី ៖ ចុះម៉េចបានពូដឹងរឿងនឹង?

រស់ ៖ ដឹង ព្រោះភូមិខ្ញុំគេធ្វើចល័ត។ វាត្រូវគ្នានឹងនិរតី គេក្តាប់យើងពីលើ ដល់ត្រូវគ្នាគេថា *«តស់ទៅលេងផ្ទះអ៊ីថែម»* ។

ធានី ៖ ពូទៅដែរ?

រស់ ៖ ទេ! ខ្ញុំនៅនេះទេ តែពួកគ្នាខ្ញុំនោះ ។ ដល់ទៅដល់ អាធ្លាប់ស្គាល់ឈ្មោះ តាលិន។ នោះស្បែកជើងនេះ ស្បែកជើងតាក្រក់ តាចាម ។ ស្រាប់តែដង្កាប់ម៉ូតូបាន គេឡើងទៅលើព្រុតែមាត់តាចាម ស្រែកមួលសាច់នោះឯង ។

ធានី ៖ ចឹងតាលិននឹងគាត់អ្នកទៅលេងផ្ទះយាយថែមនឹង?

រស់ ៖ តាលិននឹង គេខាងគាត់ប្រធានចល័ត រងពីខាងនិរតី។ គេក្តាប់ពីលើ ។

ធានី ៖ ចឹងតាលិននឹង គាត់អ្នកស្រុកយើងទេ?

រស់ ៖ ស្រុកនេះឯង ។

ធានី ៖ បន្ទាប់មករង បន្ទាប់ពីនិរតី?

រស់ ៖ បាទ!

ធានី ៖ ដល់ពេលហើយតាលិននឹងគាត់ទៅលេងផ្ទះយាយចែម?

រស់ ៖ និរតី គេនាំទៅលេង បានស្គាល់ស្បែកជើង ឬមាត់តាក្រក់ តាចាមមែន។

ធានី ៖ ហើយសព្វថ្ងៃ តាលិន គាត់នៅរស់ទេ?

រស់ ៖ នៅសព្វថ្ងៃ នៅភូមិភ្នំជញ្ជាំង។

ធានី ៖ ផ្ទះគាត់នៅកន្លែងណាទៅ?

រស់ ៖ ផ្ទះគាត់នៅលិចផ្ទះកុងលឿ ស្គាល់កុងលឿ។

ធានី ៖ កុងលឿ អត់ដឹងមួយណា ព្រោះអីភ្នំជញ្ជាំងនឹង ពេលខ្ញុំជិះមកនៅលើកន្លែងធ្វើព្រះ?

រស់ ៖ មិនទេ នៅត្បូង(ក្រោម)។

ធានី ៖ ចូលតាមយ្មោងទ្វារវត្តអត់?

រស់ ៖ អត់មានចំផ្លូវទេ ចុះមកត្បូងរួចបានមកតាមនេះវិញ(លិច)។ តាលិននេះ គាត់ប្រធានខាងចល័ត។

ធានី ៖ រងបន្ទាប់ពី?

រស់ ៖ បាទ! ប្រធានកងរយ កងអីទេ។

ធានី ៖ ចល័តទៅណាវិញប្រធានកងរយ?

រស់ ៖ ឲ្យទៅនៅម៉ាជួរខាងជង្ហៀបក្តាម អ្នកក្តាប់ចល័តជងជុំនិរតី។ ហើយក៏គាត់និយាយប្រាប់ខ្ញុំដែរ ថានារីសាន់ នារីនួននៅកូនដីរនោះ គ្នាជាជនជាតិយួន ប៉ុន្តែយួននោះយួនមិនចេះអក្សរយួនម៉ាអត្ត ហើយមិនចេះភាសាយួនម៉ាអត្តទេ យួននៅខ្មែរយូរហើយ។ គាត់ថាពេលដែលយកទៅសម្លាប់នៅវាលជង្ហៀបក្តាម។ ក៏ប្រាប់ខ្ញុំថា វេទនាណាស់ គេយកទៅអញទៅមិនបាន បៀតបតទេ ពួកចល័ត១៥នាក់។ ទៅដល់ភ្លាម សម្លាប់នោះឯងក៏សំរាតអស់បានក៏ រំលោភគ្នា។ ចាប់រំលោភរួចអីរួចលើដងជនីកបុកតាប៉ូកគ្នាឡើងឈាមរហេមរហាម វះពោះយកថ្លើម ក៏ឆាស៊ីបាត់ទៅដល់អានេះគ្នាបំរាស់មិនដឹងពេលណាបានងាប់ទេ។ តាលិននិយាយថា *"អូ!វេទនាណាស់"*។

ធានី ៖ ចឹងតាលិនឃើញតែម្នាក់ឯង ឬឃើញទាំង១៥នាក់ ទាំងកងចល័តរបស់គាត់?

រស់ ៖ ពួកកូនចៅគេប្រាប់។

ធានី ៖ កូនចៅគេប្រាប់គាត់ ឬ?

រស់ ៖ តាលិន អ្នកប្រធានៗពីលើមកប្រាប់តាលិនៗនេះគេផ្សេង។

ធានី : អ្នកនាំម្នាក់ស្រីនឹងទៅ?

រស់ : នឹងឯង ឲ្យអារងៗប្រធានកង៣០ទៅ ។

ធានី : អត់ទាន់យល់ ចង់និយាយថា តាលិន គាត់អ្នកប្រាប់ឲ្យហៅនារីសាន់ នារីនួនទៅ?

រស់ : ទេ! គេប្រាប់ថាតាលិននោះ គេបញ្ជានិរតីមកតាលិនៗ បញ្ជាមកប្រធានកង អាកងនោះ ម៉ាកង៣០ ។

ធានី : ប្រធានកង៣០?

រស់ : ប្រធាននោះ គេឲ្យវ៉ៃៗនោះ ។

ធានី : ប្រធានកង៣០ឈ្មោះអីគេ?

រស់ : មិនដឹងឈ្មោះអីទេ ព្រោះចំរុះគ្នារាប់ពាន់ រាប់ម៉ឺននាក់ ។

ធានី : ប៉ុន្តែនៅស្រុកយើងដែរ?

រស់ : ទេ! មិនមែននៅស្រុកយើងទេ ចំរុះពាសណាពាសណៃ ។

ធានី : តែប្រធានកង៣០នឹង គាត់ជានិរតី ឬក៏ជាអ្នកមកពីណាវិញ?

រស់ : ទេ! អានោះស្រុកភូមិយើង ដែលគ្រប់គ្រង៣០នាក់អី ។

ធានី : ប្រធានកង៣០នឹង ឈ្មោះអីគេ?

រស់ : ខ្ញុំមិនដឹងឈ្មោះអីទេ ព្រោះចល័តវាច្រើន ។

ធានី : ប៉ុន្តែប្រធានកងនឹង ហៅនារីសាន់ និងនារីមួយទៀតនោះ?

រស់ : តាលិនៗប្រធានកងរយៈៗប្រាប់ប្រធានកង៣០ ប្រាប់ថាពួកនិរតីនោះឲ្យវ៉ៃនារី២នាក់នោះទៀត អញមិនហ៊ានទៅបៀតទេ ឯងធ្វើម៉េចធ្វើទៅអញរករួចខ្លួនហើយ ។

ធានី : តែតាលិននឹង គាត់ដឹងថានារី២នាក់នឹង នៅក្នុងកងគាត់អត់?

រស់ : នៅក្នុងកង ។

ធានី : ចឹងតាលិននឹង ដឹងថានារីនឹងនៅក្នុងកងគាត់ ហើយជាអ្នកប្រាប់ខាងលើនឹងគេអ្នកឲ្យហៅគាត់ នឹងទៅកូនកងនឹងទៅខ្លួនឯង?

រស់ : បាទ! នោះហើយ ប្រធានកងនោះឯងគេអ្នកទៅ គេអ្នកស្គាល់ កូនកងកូនក្រុមគេ ។

ធានី : ចឹងនារីឈ្មោះ សាន់ និងនារីឈ្មោះអីមួយទៀត?

រស់ : នារីសាន់ នារីនួន បងប្អូនបង្កើត ។

ធានី : គ្រាន់គាត់ ស ថាគាត់យួន?

រស់ : ថាយួន ។

ធានី ៖ យួនដែរ តែគ្រាន់ ស?

រស់ ៖ បាទ! យួននោះនៅស្រុកខ្មែរយូរហើយ នៅមិនចេះភាសាយួន មិនចេះនិយាយភាសាតិច អក្សរមិនចេះ ។ គ្នាមកនៅយូរហើយ នៅក្នុងកូនដីរ ៗ

ធានី ៖ ចឹងប្រធានកង៣០ ត្រូវហៅនារីសាន់ ហើយនឹងនារីនួននឹង?

រស់ ៖ បាទ!

ធានី ៖ ចុះម៉េចបានពូដឹងថានារីនឹង ត្រូវសម្លាប់យ៉ាងម៉េចៗ?

រស់ ៖ វាប្រាប់ ។

ធានី ៖ អ្នកណាគេអ្នកប្រាប់?

រស់ ៖ ពួកអាប្រធានកង ប្រាប់ថា *«ម៉េចឯងធ្វើបាបគេយ៉ាងណាខ្លះ»* ។ *«អូ! ទៅវំលោភ»* ។

ធានី ៖ ចឹងប្រធានកងអ្នកប្រាប់ពូទេ?

រស់ ៖ គាលិន អ្នកប្រាប់ ខ្ញុំនេះប្រជាជនមនុស្សត្រូវគ្នា មនុស្សស្រុកភូមិនៅជុំគ្នា ត្រូវគ្នាស្គាល់ នៅភូមិនេះឯង ជិតផ្ទះខ្ញុំ ក៏និយាយលេងនេះនោះ ។

ធានី ៖ ចឹងអ្នកដែលធ្វើនឹងមិនមែនគាលិនទេ?

រស់ ៖ អត់មានទេ ។

ធានី ៖ ចុះអ្នកណាធ្វើ?

រស់ ៖ វាមិនស្គាល់ទេ អាកង៣០នោះ វាចំរុះម៉ាស្រុកព្រះនេត្រព្រះ តាំងពីភូមិណា ស្រុកណាក៏ ទៅចល័តម៉ាកន្លែង ។ គាត់បបួលខ្ញុំទៅដែរ តែខ្ញុំប្រាប់ថាអត់បានទៅ ។

ធានី ៖ អ្នកធ្វើនឹងយោធាស្រុក ឬក៏អី?

រស់ ៖ អត់មានយោធា ប្រធានកងក្តាប់៣០នាក់ ។

ធានី ៖ ប្រធានកង៣០នាក់នឹង គឺជាកូនក្រុមរបស់គាលិន?

រស់ ៖ បាទ!

ធានី ៖ គាលិន ទទួលបញ្ជាពីអ្នកណាគេមក?

រស់ ៖ ទទួលបញ្ជាពីខាងនិរតី ។

ធានី ៖ និរតីម្នាក់ដែរ?

រស់ ៖ បាទ!

ធានី ៖ ពូស្គាល់ឈ្មោះគាត់ទេ?

រស់ ៖ និរតី សួរគាលិនបានដឹង ខ្ញុំអត់ស្គាល់ដែរ ប្រាប់ដែលគ្រាន់តែខ្ញុំអត់ចាំ ។

ធានី :	ពូដែលធ្លាប់ទៅលេងផ្ទះយាយចែម ជាមួយគាត់អត់?

រស់ :	ខ្ញុំអត់ដែលទៅទេ ប៉ុន្តែយាយចែមនោះខ្ញុំក៏ភិតភ័យម្តងដែរ ។ យាយចែមនេះ គេឲ្យខ្ញុំចាស់ៗ នេះ នៅភ្នូរស្រែប្រាំងនៅខាងកើតអូរលោភ ។ ឈ្មោះមីសំប៉ៅ សំប៊ុននៅភូមិស្រែះកើតនេះ ដល់ពេលទៅនោះ គេឲ្យក្តាប់ធ្មើមេឃុំឲ្យក្តាប់ថា ម៉ាឃុំព្រះនេត្រព្រះឲ្យអ្នកក្តាប់ គាត់នាំកូន មួយនេះប៉ុននេះ កូនទើបចេះនិយាយតិចៗ ។ ដល់ពេលនោះឯង ពួកអ្នកថ្មីនេះចង់មកផ្ទះ នៅភូមិខ្ញុំ នេះចង់មកផ្ទះ ។ ដល់ចង់មកផ្ទះ ប្រាប់ថា *“ពុកប៊ុនអើយ ខ្ញុំសុំពុកប៊ុនឯងទៅនៅជុំ សហករណ៍នៅស្រែះ”* ថា *“អូ! ខ្ញុំមិនហ៊ានឲ្យទៅទេ”* ប៉ុនថាចេះ *“ព្រោះល្ងាចមិញ គេធ្វើការ ដឹងស្រាប់ហើយតើ ពួងឯកុំសេរីៗដៃសំពះក្តិត”* គេថាចេះនិយាយស្តីកុំឲ្យសេរីឲ្យសោះ ប្រយ័ត្នសេរីដៃសំពះក្តិត ។ នារីនោះវាមិនទុកទៅពេល គាត់អ្នកធូរផង *“ចុះទៅៗក៏ទៅចុះ ប៉ុននាងឯងទៅ ខ្ញុំធ្វើសំបុត្របញ្ជាក់ឲ្យទៅសហករណ៍នឹងទទួលប៉ុននេះ តែកុំដើរតាមថ្នល់ ។ តែដើរតាមថ្នល់ ងាប់ខ្ញុំហើយ”* ថា *“ទេ! ខ្ញុំដើរខាងនេះទៅចុះ”* ខ្ញុំកំពុងតែដេក ក៏ដាស់ខ្ញុំថា *“រស់ៗក្រោកធ្វើសំបុត្របញ្ជាក់ឲ្យនារីនេះតិច”* ។ ខ្ញុំក៏ថាគាត់ដែរ *“ចុះធ្វើម៉េច តិចគេចាប់បានគ្រោះថ្នាក់មេឯង”* *“ទេ! អញប្រាប់ហើយ ឲ្យដើរតាមភ្លឺ តាមអឺ កុំឲ្យដើរតាមថ្នល់”* ។ ខ្ញុំក៏សរសេរឲ្យទៅ ស្រាប់តែព្រឹកឡើងគេអត់ដើរតាមភ្លឺនោះ គេដើរមកតាមថ្នល់ គេលួចចាំ កន្លែងនិរតី ចាំត្រាក់ទ័រមានអីមកសុំគេជិះ ដល់ពួកនិរតីនោះ នារីនេះ គេធ្វីនេះ ។ គេថា *“ចុះបងស្រីឯងទៅណា”* ថា *“ខ្ញុំទៅសហករណ៍៥នៅស្រែះ”* *“ចុះអ្នកណាឲ្យទៅ?”* *“ពូ សំប៊ុន”* *“តស់ទៅជួបម៉ែចែមម៉ាភ្លែតទៅ”* ។ ក៏ឲ្យនារីទៅផ្ទះយាយចែម ទៅនោះដល់ល្ងាច ឲ្យនារីនោះឡើងមកវិញៗ ក៏បានចាប់សំប៊ុននេះហៅទៅម្តងៗ គេយកទៅវៃចោល ។

ធានី :	សំប៊ុននឹងអ្នកណាគេ?

រស់ :	ពូសំប៊ុននៅនេះឯង ។

ធានី :	គាត់ជាអ្នកណា?

រស់ :	គាត់ប្រជាជនស្រុកសាធទេ ប៉ុនដល់នោះទៅស្គាល់ឲ្យអ្នកគ្រប់គ្រងមើលម៉ាឃុំព្រះនេត្រព្រះ មើលអ្នកភ្នូរ អ្នកស្នួន ។

ធានី :	ពូសំប៊ុននឹង អ្នកគ្រប់គ្រង?

រស់ :	គ្រប់គ្រង មើលអ្នកភ្នូរ អ្នកស្នួននៅកន្លែងនោះ ។

ធានី : អ្នកស្នងនៅកន្លែងណា?

រស់ : កន្លែងខាងកើតភ្នំលាភ គេហៅអូរលាភ ។ ដល់គេវ៉ៃចោលទៅ អាកូនតូចប៉ុននេះក៏នៅនឹងខ្ញុំ ហើយក៏យំៗខ្ញុំក៏ចេះតែកុហក ចេះតែ“ពុកអើយ!” ថា“នាងអើយកុំយំ ពុកឯងទៅរកពោតឲ្យឯងស៊ីតើ តិចមកហើយៗ” នៅបាន២-៣ថ្ងៃ ខ្ញុំក៏រំដោះកូនយកមកនេះ កុហកគេដឹកមក អាបឿង ។

ធានី : សព្វថ្ងៃគាត់នៅរស់?

រស់ : សព្វថ្ងៃទៅថៃ លើកផ្ទះឡើងចំណាប់ រំដោះអាបឿងនឹងហើយ ។

ធានី : ចឹងពូសំប៊ុននឹង គាត់ស្លាប់ហើយ?

រស់ : ស្លាប់ តាមម៉ែក៏យំរហែមរហាមទៅ ក៏ថាធ្វើម៉េចយកកូនឲ្យខ្ញុំមក ។ ខ្ញុំក៏លួចកូនយកមកឲ្យម៉ែនេះឃើញ ។

ធានី : ចុះជួយនារីម្នាក់នឹង គាត់ឈ្មោះអីគេ?

រស់ : នារី២នាក់នោះ អ្នកថ្មី នៅខាងត្បូងដឹងថាឈ្មោះអី ខ្ញុំសម័យនោះក៏ភ្លេចអស់បាត់ហើយ ។

ធានី : ហើយរាល់ថ្ងៃគាត់នៅរស់ទេ?

រស់ : សព្វថ្ងៃនៅភ្នំពេញនោះ ដឹងថាយ៉ាងណា ។

ធានី : ចង់និយាយថាពេលបែក៧៩ គាត់នៅរស់មែនទេ?

រស់ : បាទ! វៀតណាមចប់ហើយ នៅរស់ ។

ធានី : ចឹងយាយចែមគាត់ហៅពូសំប៊ុនទៅរៀនវិញ?

រស់ : ទៅវ៉ៃចោល ។

ធានី : ម៉េចបានពូដឹងថាគេយកគាត់ទៅវ៉ៃចោល?

រស់ : ចុះនាំមកក៏បាត់មិនឃើញទៅ មិនឃើញអីបានថាវ៉ៃចោល ឡើងដល់សព្វថ្ងៃ បាត់ម៉ាយប់ថាធម្មតាយើងនេះគង់តែថា មកព្រឹកចឹង ល្ងាចទៅវិញហើយ ហេតុអីល្ងាចមិនឃើញយប់ ឡើងមិនឃើញ ស្អែកឡើងមិនឃើញដឹងថាវ៉ៃចោលហើយ ។

ធានី : តែគេអត់រករឿងពូដែរ?

រស់ : ទេ! អត់អីទេ ។

ធានី : ចុះកាលនឹងពូសំប៊ុននឹង ត្រូវជាអីនឹងពូបានគាត់ឲ្យសរសេរ?

រស់ : ខ្ញុំនេះកូនចៅគាត់ ដូចថាគាត់ក្តាប់ម៉ាឃុំចឹងទៅ ខ្ញុំអ្នកនៅនោះជាកូនចៅ ។

ធានី : ចឹងគាត់ជាប្រធានកងភ្ជួរ និងកងស្នងនៅភូមិយើងនឹង?

រស់ ៖ ប្រធានកងភ្នូរ កងស្លូង បាទ! ។

ធានី ៖ បើមានសិទ្ធិក្នុងការសម្រេចទៅ យាយចែមទឹង?

រស់ ៖ បាទ!

ធានី ៖ ចុះពូ ដល់ពេលក្រោយពេលមានរឿងចឹងកើតឡើង ពូម៉េចទៅ មានអ្នកណាជំនួសគាត់ទេ ពូសំប៊ុននឹង?

រស់ ៖ ទេ! ដល់ក្រោយមក ក៏មានគេជំនួសៗនោះក៏គ្នាមិនហ៊ានដែលនេះទេ គេថាយ៉ាងណាក៏គ្នាក៏មិនហ៊ានទៅណាណៃ ។

ធានី ៖ គាត់មកពីណាវិញ អ្នកជំនួស?

រស់ ៖ អ្នកជំនួសនោះខាងព្រះនេត្រទេ អ្នកជំនួសគេក្តាប់រូម ។

ធានី ៖ ឈ្មោះអីគេ?

រស់ ៖ អូ! ដឹងឈ្មោះអី កាលនោះ នៅយូរក៏វាភ្លេច ខ្ញុំវាអស់ វាដល់យូររឿងភ្លេចអស់ ៣០ឆ្នាំជាង វាត្រូវភ្លេចខ្លះ ចាំខ្លះ ។

ធានី ៖ ពូចាំទេ កាលនឹងឆ្នាំប៉ុន្មានដែលពូសំប៊ុននឹង ត្រូវគេ?

រស់ ៖ អូ! កាលនោះឆ្នាំវា៧៦ ។

ធានី ៖ ដែលពូសំប៊ុនត្រូវគេសម្លាប់នឹង?

រស់ ៖ បាទ!

ធានី ៖ ចុះឆ្នាំប៉ុន្មាន ដែលពូដឹងថាមាននារីឈ្មោះ សាន់ ឈ្មោះ នួន នឹងត្រូវគេសម្លាប់?

រស់ ៖ អូ! អានោះ ខ្ទង់៧៧នេះឯង ។

ធានី ៖ គាលិន គាត់កាន់?

រស់ ៖ គាលិន បាទ!

ធានី ៖ គាលិន គាត់មានគ្រួសារអី?

រស់ ៖ គ្រួសារនោះ ដឹងឈ្មោះអី ថាគ្រួសារគាលិន នឿន ។

ធានី ៖ ឈ្មោះ នឿន?

រស់ ៖ អឺ!

ធានី ៖ រាល់ថ្ងៃគាត់មានធ្វើការងារអីទេ?

រស់ ៖ អត់ទេ សព្វថ្ងៃគាត់ប្រជាជន មុនគាត់ទ័ពដែរ ។

ធានី ៖ តែឥឡូវគាត់នៅប្រជាជន?

រស់ ៖ បាទ! ដល់សព្វថ្ងៃគាត់រីក្រែតទៅហើយ ។

ធានី ៖ ចុះគ្រួសារគាត់?

រស់ ៖ គ្រួសារគាត់មានធ្វើអីនៅផ្ទះ ។

ធានី ៖ ចឹងពូថានៅឆ្នាំ៧៦ សំប៊ុន នឹង ត្រូវនេះចាប់បាត់ ហើយមានអ្នកថ្មីមកជំនួស ដោយសារ ជួយនារី២នាក់?

រស់ ៖ បាទ!

ធានី ៖ នារីថ្មីមកភ្នំពេញ?

រស់ ៖ បាទ!

ធានី ៖ ហើយបន្ទាប់មកទៀត ពូធ្វើអីទៀតទៅ កងភ្ជួរ?

រស់ ៖ ទេ! ខ្ញុំមិនមានអី មានភ្ជួរស្រែទៅ ក៏វាធម្មតាទៅវិញ ប៉ុនអារឿងអត់រឿងឃ្លាន វាអត់ ចឹងឯង ២០នាក់រហូតដល់អន្តរម៉ាកំប៉ុង រហូតដល់ដាច់អន្តរម៉ាកំប៉ុងទៀត២០ ។ ហើយ គល់ល្ហុង គល់ចេកធ្លាប់បានហូបអស់ហើយ ។

ធានី ៖ កងភ្ជួរនឹង?

រស់ ៖ បាទ! កងភ្ជួរ ខ្ញុំនៅជុំចាស់ៗគេអត់បានឲ្យទៅណា ។

ធានី ៖ អ្នកណាប្រធានកងភ្ជួរ?

រស់ ៖ ប្រធានកងភ្ជួរនោះឈ្មោះតារឿនៗប៉ុនងាប់បាត់ហើយ ។

ធានី ៖ ប្រធានកងភ្ជួរពូមានគ្នាប៉ុន្មាននាក់?

រស់ ៖ គ្នា៣០នាក់ ៣២នាក់ ហើយសុទ្ធតែចាស់ៗនោះ ពួកក្មេងៗគេទៅខាងចល័តខាងអីទៅខាង ឆ្ងាយ ។

ធានី ៖ ចុះពូកាលនឹងនៅ?

រស់ ៖ ខ្ញុំនៅយុវជនដែរ ប៉ុនតែគេបញ្ចូលពួកចាស់ៗ ដុតពីនោះគេទៅចល័ត ទៅស្រែអស់ ។

ធានី ៖ ម៉េចក៏ពូនៅភ្ជួរជាមួយចាស់ទៅៗវិញ?

រស់ ៖ ដឹងអីគេមកពីគេចាត់តាំងចុះទៅហើយ ។

ធានី ៖ មកពីពូស្គាល់?

រស់ ៖ អត់ទេ អត់មាន ខ្ញុំពេលនោះខ្ញុំអត់ចេះបក្សពួក ។

ធានី ៖ អត់បក្សពួក?

រស់ ៖ មិនមានបក្សពួកទេ មែនខ្ញុំនិយាយឲ្យត្រង់ឡើងខ្ញុំរហូតសម័យអាពត មិនដែលបានធ្វើប្រធានកង ប្រធានអីនឹងគេទេ នៅតែកូនក្រុមៗគេៗប្រមាថគេអីយ៉ាងណាក៏ទៅ ធ្វើម៉េចក៏ ធ្វើទៅ ធ្វើម៉េចឲ្យតែរស់អាត្មាឯង ។

ធានី ៖ ចឹងពូបន្ទាប់ពូផ្សើកហើយ ពូមិនទៅកាប់អុសធ្វើស្ករ ធ្វើអីឲ្យគេហើយក៏ចូលកងភ្នួរ?

រស់ ៖ បាទ! ចូលខាងកងភ្នួរ ។

ធានី ៖ ចូលកងភ្នួររហូតទៅ?

រស់ ៖ ចូលកងភ្នួរក៏ដល់មានទោសនេះ ដូចខ្ញុំនិយាយខាងដើម អាចាក់ស្រូវនឹងដី៩ថ្ងៃខ្ញុំថា បើសិន ១០ថ្ងៃអត់រស់ទេ ងាប់ហើយ ។ ចុះមានអីប៉ោយសំពោងពីដើមមិញ មានដីកន្ទែងអូរនេះខ្ពស់ចេះ វែក ។

ធានី ៖ ប៉ុន្មានម៉ែត្រលើកឡើងលើ?

រស់ ៖ ៤ម៉ែត្រ វែកនោះរបូតដើរទាល់បញ្ឈិតទៅឆ្ងាយ ហើយខ្លួននោះរលួសអស់ហើយ ។ ហើយ ពេលគេប្រជុំស្រេច គេថាបាត់ចបក៏ខ្ទាំង បាត់បង្គីរមួយក៏ខ្ទាំង យប់ឡើងបង្គីរដេកគើយ ចបអោបចេះ ខ្លាចគេមកលួចយកទៅធ្វើលេសវ៉ៃយើងចោល ។ ដេកតែអោបចេះ ប្រាប់ អត់ជឿទេ ក្មេងសព្វថ្ងៃអត់ជឿ សុទ្ធតែដេកវៃជនឹកស្នួរ ហើយចបអោបចេះ ។ យប់ម៉ោង ១២វៃដួងៗមើងគាត់ថាទៅ បើថាមិនទៅទេ គេដើរមើលតែឃើញដេក គេដាក់ដំបងដីងៗ រត់ចេះទៅ បើថាដឹងៗហើយបើយើងដឹងខ្លួនរត់ៗទៅ រត់ឲ្យផុតសិន ។ បើថាយើងមិនដឹង សំងំឲ្យគេវៃៗងាប់ ។

ធានី ៖ មាន?

រស់ ៖ បាទ! បើថាយើងដឹងថាគេវៃហើយ អញក្រោករត់ៗគេដំបងចោលពីក្រោយហីទៅ ។ បើថាយើងសំងំនៅនោះគេវៃងាប់នៅនោះ ។

ធានី ៖ មានទេ?

រស់ ៖ មាន ។

ធានី ៖ អ្នកណាគេដែរដឹង?

រស់ ៖ អូ! វាចំរុះច្រើនណាស់ អ្នកថ្មីអ្នកអី ដែលគ្នាស្គាំស្គមទៅក៏ធំក្បាលជន្លង់ ជួនកាលគ្មានជម្ងឺ រោគាជងក៏ងាប់ទៅ ។ ខ្ញុំពេលនោះ ខ្ញុំនិយាយឲ្យត្រង់ទៅ ខ្ញុំអត់ដែលបានឃើញគេវៃទេ ប៉ុន្តែឃើញគេចាប់ៗ ។ ដូចជា គាសាន នៅផ្ទះខ្ញុំ

តាសានអ្នកថ្មី គាត់នៅផ្ទះខ្ញុំក៏ប្រពន្ធគាត់ ឈឺៗទៅខ្ញុំទៅដល់ខ្ញុំប្រាប់ «ពុកអើយ! ម៉ែមិនស្រួលយ៉ាងហើយ គាត់ពិសារអីក៏មិនបាន ក៏ក្តួតយក ពុលឯងសុំច្បាប់គេបានម៉ាថ្ងៃ២ថ្ងៃទៅរកថ្នាំ រកឫសឈើឲ្យម៉ែគាត់ពិសារ» គាត់ក៏ចាំមើលខ្ញុំសុំគេ កាលនោះតាចាម កាលនោះពួកមជ្ឈឹមៗ តាចាមនោះគាត់ថា ម៉ាសារមុនសមុតាចាមៗថា «ទៅតែម៉ាថ្ងៃបានហើយ កុំទៅ២ថ្ងៃ» ដល់ទៅ២ថ្ងៃមិនបានទេដល់មក គាត់រកថ្នាំរកអីប្រពន្ធគាត់មិនចេះបាត់ គាត់នៅរហូតដល់២យប់ៗក៏ខ្ញុំអង្គុយនៅនោះឯង គាត់មកដល់ថា «មើលឯណា សានមកហើយ» «ទេ!ពុកគាត់មិនឃើញមក បែបម៉ែនៅមិន ស្រួលខ្លាំង» «អឺ!តែមកបានការហើយ»ៗ ខ្ញុំគិតក្នុងចិត្តថា ច្បាស់ជាធ្វើបាបគាត់ហើយ មើលទៅៗ ដល់គាត់មកទៅទាល់ល្ងាចបាន២ថ្ងៃ ដាំបាយ ដាំអី នេះនោះហូបស្រួលទាំង អស់គ្នាបបរ្ហូបទៅ ខ្ញុំកំពុងតែអង្គុយគ្នា៣នាក់ឈ្មោះ តាឈូក, តាវុននោះ អង្គុយក៏ថ្ងៃនោះផងក៏ភ្លៀងធំៗភ្លឹកៗឃើញភ្លើងអែបៗមក បានភ្លើងភ្លឺល្អ ឃើញភ្លើង «អើយ៉ា! អ្នកណាឆ្នុះភ្លើងពិលចេះ» ស្រាប់តែមកដល់ឃើញ ភ្លើងគេប្រៀប ភ្លើងតាចាមនោះគាត់ដើមយោធានោះ២នាក់នោះ ២ដើមៗ គាត់ថា «សាន ដេកណា?» ក៏សួរវុនៗថា «ពុក មិនដឹងដេកត្រង់ណាទេ» «វុនដើររកម៉ាភ្លែតមក» ខ្ញុំក៏ភ័យខ្លួនឯងដែរ ដែលក្របីស៊ីសំណាបគេរកវ៉ៃចោល ភ័យឡើងនិយាយមិនកើតទេ គិតឃើញក្នុងចិត្តថា អញដឹងក៏មិនដឹង ដែលក្របីស៊ីសំណាបផងៗ នៅនឹកភ័យខ្លួនឯង ដល់នេះឡើងវុនគាត់ដើរទៅឃើញ មកដើរ៣នាក់ គេដើរពីក្រោយៗ ដើរទៅរករទេះនេះមិនឃើញ រករទេះនោះមិនឃើញ ស្រាប់តែឃើញនៅចង្ក្រានបាយៗ ប៉ុ វុន ថា «ពុក!» «បាទ!» «នេះ ពុកចាម គាត់នាំពុកឯងទៅជួបគាត់ម៉ាភ្លែត» នៅខាងក្រៅរោងៗ ក៏តាសាននោះថា «ឈប់ ខ្ញុំពាក់អាវសិន» គាត់នោះចាស់ គាត់និយាយមួយ គាត់ថា «ឈប់ ខ្ញុំពាក់អាវសិន ខ្ញុំរកដែកភ្លើងខ្ញុំសិន» តាចាមនោះថា «មិនបាច់រកទេ ខ្ញុំជួបតែ២-៣មាត់ទេ» ចឹងក៏អត់អាវទៅ ស្រាប់តែទៅដល់នេះបែរខ្នងៗបានអាយោធានោះវាចងបានធាក់ម៉ាជើងកែង(ដៃ)ឡើងដល់គ្នាៗ គាត់ចាស់ប៉ុននោះយំហ៊ូ ក៏នាំទៅដើង ក៏ព្រឹកឡើងខ្ញុំផ្តាំមកប្រពន្ធគាត់ៗៗ ដល់ស្អែកខាងស្អែកក៏ខ្ញុំឆ្មៀតទៅយកខោអាវ យកតាំងពីដែកភ្លើង យកតាមពីស្តីឲ្យប្រពន្ធគាត់ថា «ម៉ែអើយ! នេះខោអាវពុក គាត់នៅនោះខ្ញុំក៏ប្រមូលយកមកឲ្យម៉ែហើយ ដឹងធ្វើម៉េចទេ ខ្ញុំក៏វេទនា អឺ!ក៏ស្រណោះគាត់ណាស់ អាណោចអធម៌នឹងគាត់ណាស់» ថាស្រែកអីៗ ខ្ញុំមិនដែលនេះទេ

និយាយឲ្យត្រង់ ខ្ញុំមិនដែលបានធ្វើបាបអ្នកណាកំសត់ មិនដែលបានធ្វើប្រធានកងអីសោះ បើធ្វើប្រធានកងវាសម ធ្វើតែភ្ជួរអី នេះណាចេះជួយគេទៅណា ។ សារីមមួយទៀត សារីម នោះអ្នកថ្មី គេដណ្ដឹងឈ្មោះនារីឡាន់ ក៏ត្រូវគ្នានឹងខ្ញុំនៅយុវជនដូចគ្នា ទៅភ្ជួរទៅក៏ដេកមុងជាមួយគ្នា ប្រឡែងគ្នារាល់ថ្ងៃ ដល់ខ្ញុំទៅនៅនោះ បានគេលួចអង្ករបានទៅស៊ី អនុប្រធានភូមិ គាត់ដឹងអង្ករយកទៅដោយខ្លួន ទុកនៅកន្លែងនោះម៉ាបាវ ។ ថ្ងៃចឹងបបរយប់ ឡើងដាំបាយទាំងអស់គ្នា ។ ដល់នេះទៅ វាដាច់អង្កររហូតដល់ម៉ាកំប៉ុងមាន២០នាក់ទៀត ខ្ញុំ ស្រណោះអាណិត "សារីមអើយទៅនៅជុំយើងនោះបានស៊ីបានអី" ។ សារីមទៅ ជុំខ្ញុំបាន ស៊ីបានអីធាត់ទៅ បាននៅប្រហែល៣ខែ ដល់គេឡូៗ(និយាយលេង) សារីមអើយ តាចាមមកប្រាប់ ព្រោះពួកនារីឡាន់គេនៅខាងអារក្សបាក់-ក ចំងាយប្រហែលម៉ាគីឡូម្នាក់ ហើយគាត់មកប្រាប់ ។ គាត់ថា "ទៅសួរបញ្ជាក់រឿងគូដណ្ដឹងឯង ព្រោះស្រីគេថាចង់ជួបឯងតិច" ហើយគេឡូ(និយាយលេង)ចឹង សារីមថា "គស់ទៅ២នាក់" ខ្ញុំថា "ទៅក៏ទៅ" ខ្ញុំជូនទៅ ត្រូវគ្នាបានកាំបិតអ៊ីមសៃប៉ុននេះមួយ ក៏ដើរកាប់ត្រីៗពេលថ្ងៃត្រីសំបូរនោះ កាប់បានត្រីតិចដោតតិចណាស់ ។ ទៅដល់ភ្លាម សារីមគេឈរជិតខ្ញុំ ក៏ដោះ សារីមស៊ីត្រីទៅ ក៏ចេះតែស៊ីៗ ក៏តាចាមនឹងយោធា តាចាមថា "រស់អើយ ទៅរកដេក រកពួកទុកសារីមនៅនេះយកការណ៍សិន អារឿងគូដណ្ដឹងគេវាយ៉ាងណាយ៉ាងណៃ" ខ្ញុំក៏ទៅរកដេក ។ ដល់ខ្ញុំមិនទាន់បានដេកផង ទៅដល់កន្លែង ស្រាប់តែគេរកខ្សែ "ឯណាមានខ្សែព្យួរសល់?" ស្រាប់តែមកដល់មុខសារីម ស្រែកយំ ចាប់សារីមបាត់ ។ ខ្ញុំមកក៏គិតពិចារណា គិតតែខ្លួនឯង សារីមអើយ កុំមកចងកម្មចងពៀរនឹងខ្ញុំ ។ ខ្ញុំគ្មានគោលបំណងធ្វើបាបសារីមឯងទេ មកនេះ មកដើម្បីរស់ទាំងអស់គ្នា មកគេធ្វើចេះខ្ញុំមិនដឹងទេ ខ្ញុំចេះតែដេកថា គិតក្នុងចិត្តខ្លួនឯង ។ ដល់ព្រឹកឡើងខ្ញុំតាមគន្លងទៅទៀត ទៅពីព្រលឹម ។ គេយកទៅវៃចោលត្រង់ណា តាមៗស្រាប់តែឃើញគន្លងជជុះឃើញដីគេអន្ទងប៉ុននេះមានដីតិចៗ មិនពិតទេ គន្លងមិនឃើញទៅទៀត ឃើញតែអន្លុងត្រឹមនេះក៏បាត់ ខ្ញុំដើរមកកន្លែងខ្ញុំមក ។ ប្រហែលជាកប់កន្លែងនោះឯង កប់អន្លុយ ។

ធានី : ចុះពូអត់បានមើល កាយមើលទេ?

រស់ : ទេ! មិនហ៊ានទៅកាយ សុទ្ធតែដើរ ភ្លេចពីថ្ងៃផង ដីសើម ដើរតាមគន្លង ។ ដូចត្បាញខាងនោះគេច្រើនវៃចុះឯង ខ្លះអន្លុយ ខ្លះអីក៏មានកប់ត្រឹមនឹង សន្លប់កប់ទាំងអស់ ។

ធានី ៖ ដល់ពេលពួកគិតចឹង ដូចថាពេលពួកគេឯមានយល់សប្តិពួសារីមនីឯអត់?

រស់ ៖ អត់ទេ ដល់ពេលខ្ញុំមកវិញខោអាវនៅខ្ញុំចឹងឯង ដេកម៉ាកន្លែងនោះ ដេកជុំគ្នា ដល់ខ្ញុំដេកកន្លែងគេនោះឯង សុទ្ធតែមួយ២នាក់ ។ ខោអាវគេអាពណ៌ក្រហមៗមួយនោះ តេតារុងដែរពណ៌ក្រហម ។ នឹងឈ្មោះអាភឿនៗ កូនយាយហុកនេះឯងថា "រស់អើយ! មកឲ្យខ្ញុំពាក់ អាវនេះមក" "ពាក់ក៏ពាក់" ។ ពាក់រួចក៏គេដឹកក្របីទៅភ្ជួរ អាភឿននេះសព្វថ្ងៃនៅ ។ ដល់ ពាក់ទៅភ្ជួរទៅ ស្រាប់តែខោស្រាតពីស្រេះឡើង ដឹកហ៊ុយៗទៅដឹកខាងនេះតាមភ្លឺ ប្រយ័ត្ន ជាន់សំណាបជាន់អី គេឃើញវ៉ៃចោលដឹកខាងនេះទៅផ្លូវស្រឡះ ។ ខ្ញុំថ្ងៃនោះគ្រុន ខ្ញុំមិន បានទៅ ខ្ញុំកាន់ក្របីនោះឯង ។ គេដឹកហ៊ុយៗ ក្របីនោះវាដុលអាជើងខោៗក្រាស់ឡើង ប្រូតបានឡើងគោងៗ ។ មនុស្សគោងៗនៅនឹងស្នែងក្របី ។ ចាំសួរវាៗមក ថាខ្ញុំកុហក ។

ធានី ៖ ចុះម៉េចចឹង?

រស់ ៖ គោងៗ ក្របីនោះក្រវីក្រវាត់ ក្របីនោះស្នែងឡើងធំចេះផង ជាន់ស្លាប់អត់ចេញរួចទេនៅឡើងធូន់ក្បាលវាក្រវីចេះ ។ ទៅខ្ញុំ អូ!ធ្វើម៉េចចេះ ទម្លាក់ចេះទៅជិតទៅក្របីក្រវីចេះ ។ ក្រវីៗដល់វាក្រវីខ្លាំង ប្រហែលពីនេះទៅជិរុកខ្ញុំ បានដឹងទៅនោះ ស្រែកអីយូយៗ ។

ធានី ៖ គាត់ពាក់អាវក្រហម?

រស់ ៖ អឺ! អាវក្រហម មានអីចុះអោប-ក ពីរោងមកទៅ....ចាំអាភឿនមកចាំសួរវា ។ ជាប់ជើង ខោ ហើយថា ខោនេះ ខ្មោចអ្នករឹមគាត់ទិញឲ្យផង ៦០០ អាខោក្រាស់នោះ ។

ធានី ៖ ពូថាតាមចាមៗ គាត់មកពីមជ្ឈឹមនឹង គាត់ជាស្អីអីគេ បានគាត់?

រស់ ៖ តាចាមនោះ គាត់ប្រធានសហករណ៍នេះ កាលដែលវាមិនទាន់នារីធំមក ។

ធានី ៖ ប៉ុន្តែ គាត់មកពីបស្ចឹម មកពីមជ្ឈឹម?

រស់ ៖ មជ្ឈឹម តាចាមនោះ មុនដំបូងគាត់មកធ្វើប្រធានសហករណ៍នៅនេះ ។ ប៉ុនប្រធានសហករណ៍នេះ គឺគាត់ដើរមិនបានឈប់ទេ ។ យប់ឡើង ឲ្យតែអ្នកណាបេះចេក អ្នកណានេះមានដឹងថាយកទៅវ៉ៃចោលហើយ ខ្លាំងណាស់ ។

ធានី ៖ កាច តាចាមនឹង?

រស់ ៖ កាច ៗ ដាំចេក ដាំល្ហុង ដាំអីផ្លែហើយ មិនហ៊ានបេះដែរ ដល់គេឃើញគេវ៉ៃយើងចោល ចិញ្ចឹមមាន់ចិញ្ចឹមជ្រូកក៏ដោយ ៗ ហើយពីដើមគ្រប់ផ្ទះ តែយប់ឡើងតាចាមដើរស៊ើបមើល ដើរឈ្លបៗ

ធានី ៖ ចុះតាសានដែលនេះនឹង គាត់ស្លាប់ហើយ ចុះប្រពន្ធគាត់នៅរស់ទេ?

រស់ ៖ ប្រពន្ធគាត់កាលសម័យនោះដឹងនៅ ប៉ុនដល់អត់ដឹងស្រុកស្រែណាណៃទេ ៗ

ធានី ៖ ប៉ុន្តែកាលនឹងតាសាន គ្រួសារគាត់មិនឈឺ ហើយបានគាត់រកថ្នាំមក?

រស់ ៖ អូ! តាសាននោះ ប្រពន្ធគាត់ឈឺ ៗ

ធានី ៖ ដល់ក្រោយមកគាត់ជាវិញអត់?

រស់ ៖ ដល់ក្រោយមកប្រហែលជាគ្រាន់ មិនទាន់ជាទេ បែរជាគ្រាន់ គាត់ទៅនោះវិញ ៗ

ធានី ៖ ទៅណាវិញ?

រស់ ៖ ទៅកន្លែងធ្វើការវិញ ៗ

ធានី ៖ ធ្វើការវិញនៅណា?

រស់ ៖ នៅបៀតដំបូងគោកស្វាយ ខាងត្បូងគោកលន់ ៗ

ធានី ៖ ប្រពន្ធតាសាននឹងឈ្មោះអីគេ?

រស់ ៖ ឈ្មោះ ល្ងា ៗ

ធានី ៖ យាយល្ងា?

រស់ ៖ បាទ!

ធានី ៖ ចឹងគាត់ទៅធ្វើការនៅសហករណ៍គោកលន់?

រស់ ៖ គាត់មិនមែននៅសហករណ៍ទេ គាត់នេះ គាត់ទៅកន្លែងដូចថាស្រែប្រាំង ស្រែសន្ទូងគេ ៗ

ធានី ៖ គាត់ទៅច្រូត ឬទៅស្ទូង?

រស់ ៖ ទៅស្ទូង ទៅភ្ជួរ ៗ

ធានី ៖ នៅគោកលន់ ហើយគាត់ត្រឡប់មកភូមិយើងវិញ ស្នាក់នៅភូមិយើងនេះ ឬនៅគោកលន់?

រស់ ៖ គាត់នៅភូមិនេះឯង ប៉ុនគេឲ្យគាត់ទៅធ្វើការនោះ ទាំងខ្ញុំទាំងគាត់ ទាំងគេទាំងខ្ញុំនេះឯង គេឲ្យទៅធ្វើស្រែនៅគោកលន់ អារក្សបាក់-កនោះ ៗ

ធានី ៖ ចឹងពេលតាសានស្លាប់ទៅ យាយល្ងា គាត់នៅរស់រហូត?

រស់ ៖ បាទ! នៅៗដល់ពេលវៀតណាមចូលក៏គាត់ទៅស្រុក គាត់ពុំថាមកលេងម៉ាសារ ៗ

ធានី : ធ្លាប់មកលេងពូដែរ?

រស់ : អត់ទេ ។

ធានី : ចុះពូថា(ឪពុកមា) មាវ៉ុនៗ នឹងអ្នកណាគេ?

រស់ : (ឪពុកមា) មាវ៉ុននឹង នៅត្រង់នេះឯង ។

ធានី : (ឪពុកមា) មាវ៉ុន គាត់ជាស្អីទេ?

រស់ : (ឪពុកមា) មាវ៉ុន នឹងគាត់គ្មានធ្វើស្អីទេ គាត់ជាអ្នកភូរដូចគ្នានឹងខ្ញុំ ។

ធានី : ចុះម៉េចបានគាត់ដឹងរឿងពូនិយាយមិញ?

រស់ : អង្គុយលេងដែលល្ងាចឡើងបបររួចអង្គុយយប់ អង្គុយលេងដែលមិនទាន់បានដេកលក់ ក៏អង្គុយលេងទៅស្រាប់តែចុចភ្លើងពិលមកអែប មកដល់ក៏គាត់ឈរ *«អាចារ្យវ៉ុន»* គាចាមថាចឹង *«បាទ!»* *«ឯណាអាសានដេកត្រង់ណា?»* វ៉ុនថា *«ដឹងពុក ដឹងដេកណាទេ»* ខ្ញុំនោះមិនដឹងថាគាត់ដេកត្រង់ណាត្រង់ណៃ ឲ្យដើររកម៉ាភ្លែតចេះទាំងខ្ញុំទាំងអី ។

ធានី : ចឹងពូនៅជាមួយ(ឪពុកមា) មាវ៉ុននឹង? គាត់ឈ្មោះវ៉ុន ឬមេ?

រស់ : មា វ៉ុន ប្រុស តិចគាត់នៅតើ ។

ធានី : ចឹង មារបស់ពូ មិនមែនមាបង្កើត គ្រាន់យើងហៅមា?

រស់ : បាទ! ហៅ មា ។

ធានី : មាវ៉ុន នឹងពូដើររកគាសាននឹង រកឃើញហើយប្រាប់ឲ្យមក?

រស់ : បាទ! គេប្រាប់ ។ គ្រាន់ហៅមកគេដើរតាម ។ គេដើរតាមពីយើងពីក្រោយ ឯងឈររទេះនេះគេឈរចេះ *«រកពុកមិនឃើញទេ»* *«រកមើលទៀត»* ។ ក៏ដើរទៅទៀត គេដើរតាមពីក្រោយ បានន័យថាគេនៅនេះឲ្យយើងដើរណា គេមិនទុកចិត្តយើង គេដើរតាមពីក្រោយជាប់ ។

ធានី : ចុះពូស្គាល់យាយចែមច្បាស់ទេ?

រស់ : យាយចែម ខ្ញុំមិនសូវស្គាល់ច្បាស់ទេ ប៉ុនធ្លាប់ឃើញគាត់ខ្លះដែរ ។

ធានី : ធ្លាប់ឃើញខ្លះដែរ?

រស់ : បាទ! ដែលខ្ញុំទៅភ្ជួរនៅជុំបុណ្យ ខាងកើតភ្នំលាភ អូរលាភនោះ ធ្លាប់ឃើញគាត់ម៉ាភ្លែតៗ ។

ធានី : រូបរាងគាត់ម៉េចដែរ?

រស់ ៖ ប៉ុនឲ្យស្គាល់គាត់ឲ្យច្បាស់នេះ ទំនាក់ទំនងនិយាយលេង គាត់មកដល់ទីប៉ុន្មានមិនដែលទេ ដឹងថាគាត់យាយថែមៗ ដឹងតែប៉ុននោះ ។ មាឌខ្មៅ វៀងស្គម ។ យាយថែមនោះក្រហមឆ្អិនឆ្អៅណាស់ ។

ធានី ៖ មាឌគាត់ធំតូច?

រស់ ៖ មាឌគាត់ស្គម គាត់ចាស់ហើយ វៀងស្គម ។

ធានី ៖ ចាស់អាយុប៉ុន្មាន?

រស់ ៖ អូ! កាលនោះដឹងអាយុប៉ុន្មាន ប៉ុនគាត់ចំណាស់វៀងគ្រាន់ហើយ ប្រហែលខ្ទង់៥០ ។

ធានី ៖ កាលសម័យនឹងគាត់ខ្ទង់៥០?

រស់ ៖ បាទ! ប្រហែល៥០ជាងយាយថែម ។ ហើយសូម្បីតែប្តីគាត់ថាក្របីនេះចេះចុះមួយពេល ដែលរត់ទៅនោះពួគាមគេនិយាយទេ រត់ទៅនៅព្រៃ គាត់ថា "យើងទៅនៅស្រុកភូមិវិញ" ឡើងវៃប្តីចោល គេថា ។

ធានី ៖ យាយថែមសម្លាប់ប្តីខ្លួនឯង?

រស់ ៖ បាទ!

ធានី ៖ ប្តីគាត់ឈ្មោះអីគេ?

រស់ ៖ មិនដឹងប្តីឈ្មោះអីទេ ខ្ញុំក៏មិនសូវព្ញពួកអ្នកទោសនិយាយប្រាប់ គាត់ថា "គាត់នៅសុខចិត្តដាច់ជើងម៉ាចំហៀង គាត់នៅជើងម៉ាចំហៀង ក៏គាត់ធ្វើខ្មែរក្រហមដែរ" ។

ធានី ៖ តែជើងគាត់អត់មានដាច់?

រស់ ៖ ទេ! អត់ទេ គាត់ប្តេជ្ញា ប្តីនាំមកស្រុកមកភូមិ អត់មកទេ ចង់សម្លាប់ប្តីចោលទៀត ។

ធានី ៖ តែអត់បានសម្លាប់ណា?

រស់ ៖ អត់បានទេ ។

ធានី ៖ ប៉ុន្តែអត់ដឹងថាប្តីគាត់ឈ្មោះអីទេ?

រស់ ៖ បាទ! អត់ដឹងទេ ។

ធានី ៖ ហើយដឹងប្តីគាត់នៅណា?

រស់ ៖ មិនដឹង វានៅខាងនិរតី មិនដឹង ។

ធានី ៖ ចឹងយាយថែមកាចអត់?

រស់ ៖ អូ! កាចណាស់ យាយថែមនោះ បើលោកគ្រូឯងចង់ដឹងនោះទៅស្រាវជ្រាវម៉ាជួរភ្នំលាកភ្នំត្រយោងនោះ អានោះបានច្បាស់លាស់មែនទែន ។

ធានី : មានអ្នកនៅនឹងដែរ?

រស់ : នៅ បងប្អូនអ្នកភូមិនៅនឹងឯង ។

ធានី : ពូស្គាល់ពួកគាត់នៅនឹង?

រស់ : ភ្នំត្រយោង ទៅតែមេភូមិគេដឹងហើយ ភ្នំត្រយោង ភ្នំលាភ គឺខ្មោចនៅសម័យនោះ ដូចជា គ្រាប់ដំឡូងជ្វា ខ្ញុំទៅចងគោ ទៅឃ្វាលគោ ហើយកន្លែងនោះឯង ឧបមាថាអ្នកដែលមាន កំហុសអីនេះនោះ ដូចជាភូមិខ្ញុំ២-៣នាក់ គេយកទៅនោះ ។ ដឹងថាវៃគោស៊ីទៅក៏ គេចាប់ យកទៅនោះទៅ គេយកទៅខ្ញុំក៏មិនដែលបានទៅជិតគេទេ ប៉ុន តាឆយនោះ គាត់រត់ទៅ ។ តាឆយថា *"នៅភ្នំត្រយោងនោះ សឹងថាមិនស្រួលខ្លួនមិនមានរឿង គេគឹងណាដល់ហើយ"* គាត់ថាឃើញអាចន ចយ កូនតាសាន ។ ម៉ោង១២ចេះវៃ ដួងចែកបបររួច បានម៉ា សន្ទុះវៃដួងទៀត ។ វៃដួងថាធ្វើការមិនទាន់ទេ គេដើរមើលកន្លែងដើរទៅឃើញ គេដេញ ចោល...ត្រូវម៉ាដំបងចេះ ដួលក្រឹបដឹងខ្លួនឆាប់រត់ទៅទៀត បើថាមិនរត់ទៅទេ គេវៃស្លាប់ នោះឯង ។ គេថាអូ!វេទនាណាស់ អញទៅមើលឃើញកន្លែងទោស គេដាក់នៅនោះ ថា ខ្មោចស្លាប់ដល់ហើយ ខ្ញុំឃើញហើយឡើងទំរើស អ្នកណាទៅនៅគេយកទៅឲ្យយាយចែមឲ្យ កូនចែមវៃចោល ។

ធានី : ចឹងបើតាមពូដឹង តាំងពីតាក្រក់ តាសន តាអី យាយចែម មួយណាកាចជាង ហើយមួយ ណាសម្លាប់ច្រើនជាង?

រស់ : ២នឹង គឺថាមិនខុសគ្នាទេ វាបើគិតទៅវាមិនខុសគ្នា ប៉ុន្តែពួកយាយចែមនោះ តាចាមនេះក៏ វៃមិនតិចដែរ ។ ប៉ុន្តែពួកនិរតីមក វាវៃគ្រាន់ថាវៃអ្នកពួកជាប់ខ្សែរយៈ ដូចជាទាហាន ដូច ជាធ្វើការងារអីផ្សេងៗ អានោះគេវៃ នេះពួកនិរតីមក ។ សរសើរតិចទៅចុះ វាអនុគ្រោះ ខ្លះដែរ បើអាបស្ទឹមនោះដូចមិនចេះភាសាខ្មែរ ។ និយាយពាក្យល្អយ៉ាងណា ក៏ថាឯង អាក្រក់ ថាឯងថានេះថានោះរកវៃចោល ។

ប្អូនស្រី : បងខ្ញុំបានពួកនិរតីមក កុំអីគេយកវៃចោល បានពួកនិរតីជួយកុំអីយកទៅវៃចោល បងខ្ញុំ ។

រស់ : ថាអូ! យ៉ាប់ណាស់ អត់មានចេះរកយុត្តិធម៌ រកខុស រកត្រូវឲ្យគ្នាទេ ។ ចុះសម័យនោះ លោកគ្រូឯងដឹងស្រាប់ហើយ សូម្បីតែគោស៊ីស្រូវក៏ខ្មាំង បាត់ចប បាត់បង្គីរក៏ខ្មាំង គេគិត អារឿងកំប្លេរ រឿងវៃនឹងហើយ ។ ហើយដុះនៀមនេះ និយាយពីសក់នោះ៣ដើម អាគ្នា ឈើនោះរលួយអស់ សក់នៅក្បាលជន្លង់ ឡើងធំតែក្បាល ។ មុននឹងឡើងភ្លឺស្រែ ទាល់តែ

ស៊ីត្រីឆៅសិន ភ្លឺស្រែឡើងកំពស់នេះ ប៉ុនឡើងមិនរួច ឡើងទៅថយមកវិញៗ ចាំសួរគាត់ស៊ីឆៅអស់ម៉ាកំប៉ុងបានឡើងភ្លឺស្រែនឹងរួច ។ បានវេទនាណាស់ ។ ហើយថាគោលបំណងរបស់វាខ្មែរក្រហមកាលសម័យនោះ ដែលវាគ្រប់គ្រងវាជីកស្រះកន្លែងនេះមួយហើយជីក តែលើភ្នំនោះ អាណាទៅជីកទឹកកើត ។ មិនមែនជីកសម្រាប់ដឹកទឹកទេ ជីកសម្រាប់នឹងវៃ បងប្អូនទាំងអស់គ្នា ។

ធានី : តែបានដាក់ បានសម្លាប់អត់?

រស់ : អត់ទាន់បាននេះទេ វាដល់ជីកស្រះអីនេះនោះ ពួកនិរតីមកការងារគេផ្សេងទៅ ។ ប៉ុនគោល បំណងដែលវាជីកនោះ មិនមែនជីកសម្រាប់ដឹកទឹកទេ ស្រះនោះទៅលើនោះ ។ វាទុក សម្រាប់វៃចោលចឹងឯង ស្រះនោះ ស្រះនេះ វាសម្រាប់ថាបញ្ជូនក្នុងស្រះក៏ធ្វើមិនធ្វើ វាវៃចោល ។ ឬដំណើរផែនការ វាទុកតែនារីស្អាតៗ តែម៉ាម៉ឺននាក់ ដែលឮតាមនេះ ។

ធានី : ពូឮតាមអ្នកណាគេ?

រស់ : ឮតាមឱ្យបស្សរមាននិយាយថា ។

ធានី : អ្នកណាគេ?

រស់ : ទេ!ខ្ញុំឮតាមគេថាទេ ដូចឮណាទេគ្នាគេច្រើន គេទុកតែនារី១ម៉ឺននាក់ ហើយគេទុកតែស្អាតៗ គេឲ្យចិននោះមកឲ្យខ្មែរយើងទៅជាចិនណាទេ វៃអាប្រុសៗចោលឲ្យទាំងអស់ ប៉ុនគម្រោង ការវាមិនដឹងយ៉ាងម៉េច ចុះដូចយ៉ាងណាទេ អានេះគ្រាន់តែឮៗ ។

ធានី : ឮៗ?

រស់ : បាទ!

ធានី : ចឹងយាយថែមនឹង ពូដែលធ្លាប់ឃើញគាត់ផ្ទាល់?

រស់ : ខ្ញុំគ្រាន់បានម៉ាឃើញៗ មិនដែលបាននិយាយគ្នាម៉ាមាត់ ២មាត់ទេ ព្រោះសម័យនោះខ្ញុំមិន ដែលហ៊ានទេ ។

ធានី : ពូទៅណាបានឃើញគាត់?

រស់ : ខ្ញុំធ្វើស្រែនៅនោះ ដែលថាពូសំប៉ិននៅសង្កាត់ភ្នំលាភ គាត់នោះនៅភ្នំលាភឆ្លងតាមថ្នល់បេះ ហើយខ្ញុំនៅខាងកើតអូរលាភៗដែលរោងគេ លក់សាំង លក់ម៉ាស៊ុត ។

ធានី : មានអូរមួយ ស្ពានធំ?

រស់ : បាទ! អូរនោះឯងទៅមកៗក៏ឃើញគាត់ បរទេះតាមថ្នល់មើលទៅឃើញ ហើយនិយាយមិនបាននិយាយជាមួយគាត់ ។

ធានី : ចុះដូចថាពូធ្លាប់បួសជាព្រះសង្ឃអីចឹង ដល់ពេលឃើញទង្វើរ គាចាម គាសន ដែលគាត់បានធ្វើពីមុនៗមក ហើយក៏ដូចជាយាយថែមបន្តគ្នាចឹង តើពូយល់ថាម៉េចដែរ?

រស់ : អូ! យល់ម៉េចទេ លោកគ្រូអើយ ពេលនោះក៏រំភើបក្នុងចិត្ត អាគិតទៅគេមិនសូវជាគិតគិតអារឿងខ្លួនឯង ថាអញមិនដឹងធ្វើរម៉េចទេ មិនផុតពីស្លាប់ទេ បើមិនស្លាប់នឹងដាច់ពោះទេ ស្លាប់នឹងគេវ៉ៃចោល គិតតែក្នុងចិត្តរឿងខ្លួន ។

ធានី : ចឹងពូធ្វើម៉េចទៅ?

រស់ : ទេ! បេះតែនៅ បេះនៅផ្សងសំណាងក៏បានរស់ទៅណា ។ សម័យនោះលោកគ្រូដឹងស្រាប់ ហើយតែលួចស្រូវវាតិចគឺគេថាខ្មាំង ។ ពាក្យថាខ្មាំង គេសុទ្ធតែវ៉ៃចោលទាំងអស់ ។ ហើយខ្ញុំអ្នកបួសអ្នករៀបមានអី ប៉ុនដល់ពេលឃើញចាប់គេរឿងនោះសម័យនោះចប់ទៅហើយ ជារឿងធម្មតា គិតថាអារម្មណ៍នៅក្នុងចិត្ត អញធ្វើម៉េច ដើម្បីកុំឲ្យគេចាប់អញ ធ្វើបាបអញ គិតតែយករស់រឿងខ្លួន ។ ហើយបានអីស៊ីអីចុក គេក៏មិនដែលចែកយើង យើងក៏មិនដែលចែកគេ រស់តែរឿងខ្លួន ដឹងរកណាឲ្យបានផង ទៅណាក៏គល់ចេក គល់ល្ហុង សំបកដំឡូងមី ខ្ញុំធ្លាប់អស់ហើយ ធ្លាប់ហូប សំបក មិនបាច់ដល់សាច់ រហូតដល់ប៉ុនមេដៃ ដំឡូងមីប៉ុនមេដៃម៉ាថ្ងៃក៏មានដែរ ថាវេទនាណាស់ ។ ហើយខ្ញុំទាំងគេទាំងខ្ញុំ មិននឹកស្មានថាបានរស់ទេ បើគិតថា មិនស្លាប់នឹងគេវ៉ៃចោលទេ មានតែស្លាប់នឹងដាច់ពោះនឹងឯង ។ ប៉ុនដល់នេះឡើងក៏បានរស់ ។ ក៏ខ្ញុំនិយាយតាមត្រង់ទៅ ខ្ញុំឃើញក្រមង៉ុយប៉ុនបាតដៃមួយ ។

ធានី : ស្អីគេ?

រស់ : សៀវភៅក្រមង៉ុយ គេទស្សន៍ទាយរឿងពុទ្ធទំនាយ ធ្វើម៉េចបានទៅឃើញ បានតិចនឹងឯងមើលទៅក៏ បងថ្លៃខ្ញុំបេះប្រាប់អ្នកសៀង ថាអ្នកអើយប្រុងប្រយ័ត្នមែនទែន ប្រុងរក្សាខ្លួនទៅ ព្រោះក្នុងក្រមង៉ុយនេះគេដាក់បេះ ខ្ញុំថាតិច “ឥឡូវ៧៨ នៅ២១ខាងក្រោយ កូនចៅកុំបណ្ដោយឲ្យលិចលង់ក្នុងសង្គ្រារ មានពាក្យចាស់ដំណាល ថាព្រះសាសនា ទំនាយក្បួនតំរាលថានឹងរាវ ហើយរីកក្នុងចិត្ត” ៧៨ត្រូវរីកនោះឯង ។ គេថា៧៨ត្រូវរស់ហើយ គេថា៧៨ នៅ២១ខាងក្រោយ កូនចៅកុំបណ្ដោយ ។ ខ្ញុំថា៧៨មុខតែរីកហើយ ប្រុងប្រយ័ត្នខ្លួនមែនទែន ។ ដល់៧៨មែន អាពុទ្ធទំនាយនោះគេស្ដាយមក ។

ធានី : ស្លាប់ច្រើន ឬរស់ច្រើន?

រស់ : ខ្ញុំប្រាប់បងថ្ងៃ ឲ្យប្រុងប្រយ័ត្នរក្សាសីល រក្សាខ្លួនផង តែ៧៨នេះ ។ នេះសៀវភៅឲ្យគាត់ទៅ ខ្ញុំមើលឡើងចាំ ។

ធានី : ចុះសៀវភៅនឹងមានទៀត?

រស់ : អត់ឃើញទេ ឲ្យទៅគាត់ទៅ គាត់ស្រមៃមើលទៅក៏គាត់មើលបាត់ទៅ ។ សៀវភៅពុទ្ធទំនាយនោះ ទស្សន៍ទាយមិនសូវខុសទេ ដែលព្រះមុនបរិនិព្វានទៅប្រាប់ពួកអនន្ទពួកអីថា សាសនាគថាគតនោះ ត្រូវរីកចំរើន ប៉ុននេះវាត្រូវរាល ប៉ុននេះវាត្រូវដាច់នេះណា ទស្សន៍ ទាយមកស្រេច ។ ខ្ញុំមើលអានោះទៅ បានជាខ្ញុំខំធ្វើល្អនឹងគេទៅ ក៏បានចៀសផុតដល់ ៧៨រំដោះមែន ។

ធានី : ចឹងពេលរំដោះ ពូវៀតណាមចូលមកដល់នៅឆ្នាំប៉ុន្មាននៅភូមិយើង?

រស់ : វៀតណាមរំដោះវាចូល៧៩ ។

ធានី : ៧៩ខែប៉ុន្មាន ពូចាំ?

រស់ : កាលនោះ វៀតណាមវាអត់បានមកនេះទេ ដូចថាគេមកតាមថ្នល់នៅនោះ ក៏ខ្មែរក្រហមរត់ ទៅអស់ ក៏យើងនៅនេះ ខ្មែរក្រហមរត់អស់ មានព្រៃណាខ្មែរក្រហមបាននៅ ។ ខ្មែរ ក្រហមវាបើរថក្រោះតាមថ្នល់ ដេញដល់ណាណែរត់ទៅព្រៃណាអស់ ។

ធានី : ចុះកាលនឹងគេមានកៀរប្រជាជនយើងនៅនឹងទៅដែរអត់?

រស់ : កាលមុនដំបូងកៀរទៅម៉ាចំនួនប្រហែលរទេះ២-៣ ដល់កៀរទៅម៉ាចំនួនទៅ ឈ្មោះតាសុននេះឯង កៀរទៅគាត់ក៏លួចមកវិញតែម្តង ។ ក៏គេបររទេះទៅហួសចេះទៅ គាត់ធ្វើជាបរមក មិនដល់គេ អាខ្លះក៏ចេះបាក់ព្រែកបាក់អី នៅចង់នោះទៅ គេទៅបាត់រួចមកវិញ ។

ធានី : ចឹងពូអត់បានទៅនឹងគេទេ?

រស់ : ហ៊ឺ! ខ្ញុំអត់បានទៅនឹងគេទេ ។

ធានី : ក្រោយពី៧៩មក ពូធ្វើអីវិញ?

រស់ : បាទ! ដល់ក្រោយ៧៩មក គេឲ្យខ្ញុំធ្វើអនុប្រធានក្រុមយើង១០គ្រួសារ។ ធ្វើស្រែប្រវាស់ដៃ ។ ពេលនោះក៏មានអ្នកថ្មីផង អ្នកនេះចាស់ផង ហើយពេលនោះគោអីក៏មិនសូវមានទេ ។ ដូច្នេះ១០គ្រួសារចឹង ក៏គោ២-៣នឹមជួយភ្ជួរជួយអីដើម្បីរស់ ឲ្យបានរស់ទាំងអស់គ្នាទៅ ។ ដល់ពេលបានរឹងដៃ រឹងជើងទៅ

អ្នកថ្មីក៏គេទៅស្រុកគេខ្លះទៅ យើងនេះក៏រឹងដៃ រឹងជើងក៏ បែកគ្នាទៅធ្វើរៀងខ្លួន ចេះឯង ។

ធានី : ចឹងពូរៀបគ្រួសារតាំងពីឆ្នាំប៉ុន្មាន?

រស់ : ខ្ញុំបានតាំងពីសម័យអាពត ។

ធានី : រៀបជាមួយគាត់?

រស់ : នោះឯង ខ្ញុំបានពីឆ្នាំ៧៧ ។

ធានី : ចឹងនៅឆ្នាំ៧៧រៀបគ្រួសារ?

រស់ : បាទ!

ធានី : រៀបនឹង ពូពេញចិត្តរៀបខ្លួនឯង ឬមួយក៏ម៉េច?

រស់ : ទេ! វាប៉ុន្មាន៥០គូ គិតតែចាប់ដៃគ្នានៅសម័យប៉ុលពត ៧៧ ។

ធានី : ចឹងចាប់ដៃគូយ៉ាងម៉េចជួយប្រាប់?

រស់ : នែក! សម័យប៉ុលពត លោកគ្រូ ឧបមាថាខ្ញុំស្រឡាញ់អ្នកណាមួយ ស្រឡាញ់នេះមួយក៏ ជួនកាលក៏ប្រាប់ម៉ែឪទៅ បើថាយើងនៅចល័តចេះ ក៏ប្រាប់ប្រធានកងយើង ថាឥឡូវខ្ញុំ ស្រឡាញ់ឈ្មោះកនេះមួយ ឥឡូវស្នើខ្ញុំតើគេយកខ្ញុំឬមិនយក ។ បើថាគេយកទៅ ចាំរង់ចាំ ខែណា ថ្ងៃណា ស្រេចគេថាម៉ាខែទៀត មាន៥០-៦០គូ ។ ពេលទៅដល់គេហៅឈ្មោះក និងឈ្មោះខ យើងទៅចាប់ដៃទៅ ។

ធានី : ចឹងឈ្មោះពូជាមួយឈ្មោះមីងទៅ?

រស់ : បាទ!

ធានី : ជាមួយមីងអី?

រស់ : មីងទី ។

ធានី : ហៅទៅ?

រស់ : បាទ! ហៅទៅ ជួនកាលក៏ដល់ខ្ញុំមិនសូវស្គាល់ក៏ចាប់ប្រឡូំ វាយប់ ។

ធានី : ចឹងដល់ពេលពូការនឹងពេលយប់ទេ?

រស់ : យប់គេហៅយប់ ។

ធានី : គេហៅឈ្មោះ ហើយចាប់ប្រឡូំមីង?

រស់ : ទេ! អ្នកផ្សេងខ្លះទៀត ដូចថាអ្នកថ្មី និងអ្នកចាស់ក៏បានឡើងស្រឡាញ់មិនបានឃើញគ្នា ជួនកាលឈ្មោះវាដូចគ្នាទៀត របស់អញដឹងដល់ទៅមិនដឹងទេ ។ ហើយរៀបការនោះឯងក៏

វាមិនមានអីជាធំដុំទេ គេគ្រាន់ថា គេអប់រំយើងតិចដែរ អប់រំថាអប់រំនេះនោះ យើងប្តេជ្ញា ដើរតាមគេទៅណា ។ កុំឲ្យធ្វើចេះធ្វើចុះវាខុសពីអង្គការដឹកនាំនេះនោះទៅ គេអប់មកផ្ទះវិញ ទៅ ។

ធានី : ចុះកាលនឹង អ្នកណាគេអ្នកចូលរួមក្នុងការមកធ្វើចាប់គូនឹង?

រស់ : នែក! ប្រធានមេឃុំគេ ។

ធានី : មេឃុំគេឈ្មោះអីគេ?

រស់ : ឃុំគេនោះ កាលនោះតាផន ។

ធានី : តាផន?

រស់ : បាទ!

ធានី : នៅឃុំណាវិញ កាលនឹងពូរៀបការ?

រស់ : ឃុំព្រះនេត្រព្រះនេះឯង ។

ធានី : ចុះក្រែងថាឈ្មោះធំនោះ?

រស់ : ធំនេះ គាត់ប្រធានសហករណ៍ មកក្រោយ ។ កង់ខ្ញុំនៅបាននោះ កាលនោះនៅបស្ទឹមនៅ ឡើយ ។

ធានី : ចឹងកាលពេលដែលធំនឹងមកឆ្នាំប៉ុន្មាន?

រស់ : ណា និរតី

ធានី : ហ្នឹងហើយខាងនិរតីមកឆ្នាំប៉ុន្មាន ដែលគាត់មកគ្រប់គ្រងនៅសហករណ៍?

រស់ : និរតីមកនេះ ចុង៧៧ ។

ធានី : ចឹងពូការដើម?

រស់ : បាទ!

ធានី : ចឹងពូការនៅដើម៧៧?

រស់ : បាទ! ប្រហែលជាពាក់កណ្តាល ៧៧ ។

ធានី : គ្រាន់ការហើយបានខាងនិរតីមក?

រស់ : បាទ!

ធានី : មកពេញ?

រស់ : បាទ!

ធានី : ចឹងស្រុកព្រះនេត្រព្រះឈ្មោះ ផន?

រស់ ៖ បាទ!

ធានី ៖ គាត់មកពីបស្ទឹម?

រស់ ៖ បាទ!

ធានី ៖ បន្ទាប់មកផន នឹងគាត់និយាយម៉េចខ្លះ បានពូរៀបការហើយ?

រស់ ៖ ចេះលោកគ្រូខ្ញុំនៅភូមិចេះ ម៉ែឪបានទៅសាក់សួរ សួរម៉ែឪនិងម៉ែឪ សាក់សួរពិនិត្យ ។

ធានី ៖ ហើយបានយើងស្នើទៅ?

រស់ ៖ បាទ! ស្នើទៅ ។

ធានី ៖ ស្នើទៅយប់ឡើងបានគេហៅៗឈ្មោះ?

រស់ ៖ បាទ! ប៉ុននេះយើងទៅរាយការណ៍ឲ្យប្រធានសហករណ៍គេ ។ សហករណ៍គេកត់ឈ្មោះទៅ ចាប់ផ្ដើមខែណាដែលគេចាប់គូដៃគ្នា ក៏គេហៅទៅ ។

ធានី ៖ ចុះប្រធានកងចល័តពូឈ្មោះអី?

រស់ ៖ ខ្ញុំ មានតែបងធំទេ ។

ធានី ៖ ធំ គាត់ប្រធានសហករណ៍?

រស់ ៖ ប្រធានសហករណ៍ ខ្ញុំនេះមិនដែលបានចល័តទេ ខ្ញុំនៅនឹងភូមិ ។

ធានី ៖ គ្រាន់តែពូប្រាប់ឈ្មោះទៅប្រធានសហករណ៍ពូ?

រស់ ៖ បាទ! ម៉ែឪប្រាប់ប្រធានសហករណ៍ ថាកូននឹង ។

ធានី ៖ ប៉ុន្តែ ធំនឹងគាត់មកហើយ?

រស់ ៖ បាទ! មកហើយ ។

ធានី ៖ ពូថាគាត់មកនៅចុង៧៧?

រស់ ៖ បាទ!

ធានី ៖ ហើយតាផន គាត់នៅខាងបស្ទឹម?

រស់ ៖ បាទ!

ធានី ៖ យាយចែមមក?

រស់ ៖ ប៉ុនតាផននេះ លោកគ្រូ តាក្រុក់នេះគេចាប់ទៅហើយ តាផនគេអត់បានចាប់ទៅទេ នៅធ្វើការជុំនិរតីនៅជុំគ្នា ។

ធានី ៖ ចឹងតាផន នៅរស់រាល់ថ្ងៃ?

រស់ ៖ តាផន ប្រហែលជានៅរស់រាល់ថ្ងៃ ។

ធានី ៖ ដឹងនៅណា?

រស់ ៖ ព្រោះនិរតីមក តាជន គេខ្សែទៅខាងជុំនិរតី ស្រុកជិតគ្នានោះទៅ និរតីគេអត់ធ្វើបាប នៅធ្វើការជុំនិរតីនឹង ។

ធានី ៖ ចឹងអត់ដឹងថាតាជនរាល់ថ្ងៃគាត់រស់នៅណា?

រស់ ៖ អូ! មិនដឹងទេ ព្រោះសម័យវៀតណាមចូលមក រត់ទៅព្រៃនោះ ។

ធានី ៖ ចឹងតាជន បន្ទាប់ពីតាក្រក់យាយថែម ចូលមកយូរហើយ ឬពេលដែលតាក្រក់ចាប់ហើយ បានយាយថែមមកដល់?

រស់ ៖ តាក្រក់នៅចេះទៅ នៅដឹកនាំនេះឯង និរតីគាត់មកដែរ ។

ធានី ៖ មកដែរ អត់ទាន់?

រស់ ៖ អត់ទាន់បានធ្វើបាបធ្វើកំសត់អីទេ នៅសិននៅម៉ារយៈនោះឯងប្រហែលជា២-៣ខែ ក៏ពួកគាក្រក់អីនេះ វាមិនបានមានមាត់នៅស្មៀមឪដងដាក់គេទៀត វាមិនមែននេះឪឌងពួកនិរតី នេះវាស្រឡាញ់ផ្អែៗលាងខ្លួន ដាក់បាយ ។

ធានី ៖ ស្រឡាញ់អីគេ?

រស់ ៖ ផ្អែ សុទ្ធតែដៀលគ្នាថាមនុស្សស្រឡាញ់ផ្អែ មានប្ដីផ្អែទៅចុះ ។

ធានី ៖ តាក្រក់នឹងថាឲ្យយាយថែម?

រស់ ៖ បាទ!

ធានី ៖ ចឹងយាយថែមខឹងចាប់អស់ទៅ?

រស់ ៖ ចាប់អស់ម៉ាខ្សែ ។ ទេ! ទោះបីតែមនុស្សក៏ចាប់ដែរ រឿងវាត្រូវវៃបំបាក់ម្នាងៗដែរ ។

ធានី ៖ ចឹងតាជនលើៗ?

រស់ ៖ ដល់តាជន នេះ អត់មានវៃនេះទេ ធ្វើបាបអីទេ រស់ជុំនិរតីៗ និរតីទៅណា គាត់ទៅត្រង់នឹង ។

ធានី ៖ ចឹងពេលពូការ តាជន នឹងគាត់អ្នកប្រកាស?

រស់ ៖ បាទ! តាជននឹង អ្នកហៅប្រកាស ។

ធានី ៖ កាលពេលពូការ គេចែកផ្ទះ ចែកអី ឬក៏មានគេជប់លៀបអីឲ្យទេ?

រស់ ៖ អត់ទេ អត់មានជប់លៀងទេ មកដល់ផ្ទះចេះ បើថាម៉ែឪខាងប្រុស ខាងស្រីចេះ ថាបើមានមាន់ក៏លួចលាក់ទៅ ដើម្បីផ្អាច់ខ្មោចនេះនោះទៅ ។ បើខ្វះមិនមានមាន់ អត់ទៅណា ។

ធានី ៖ តែពូ ឪពុកម្ដាយពូ?

រស់ : ខ្ញុំនេះ គេទុកមាន់មួយ ។

ធានី : ម៉ែឪដឹងទាំងអស់សងខាង?

រស់ : បាទ!

ធានី : ចឹងពូរៀបការតាំងពី៧៧រហូត ហើយមកដល់រាល់ថ្ងៃពូមានមុខងារធ្វើអីដែរ?

រស់ : ខ្ញុំដល់ពេលក្រោយមក វៀតណាមចូលមក ខ្ញុំធ្វើអនុប្រធានក្រុម ។ បន្ទាប់ពីធ្វើអនុប្រធានក្រុម ខ្ញុំធ្វើប្រធានក្រុម ។ ដល់ប្រធានក្រុមគាត់ចាស់ជរាពេក គាត់ឲ្យខ្ញុំធ្វើប្រធានក្រុម ។

ធានី : ឆ្នាំប៉ុន្មានប្រធានក្រុម?

រស់ : ៨២ ។ ដល់ពេលបាន៨៣នេះ គេឲ្យខ្ញុំធ្វើអនុប្រធានភូមិ ។

ធានី : អនុភូមិយើងនេះ?

រស់ : បាទ! អនុប្រធានភូមិ ។

ធានី : អនុភូមិស្រះកើត?

រស់ : បាទ! ស្រះកើតនោះឯង ។

ធានី : ហើយម៉េចទៀត?

រស់ : អនុប្រធានភូមិទៅ ពេលនោះលោកគ្រូអើយដូចថាវាវេទនាដល់ហើយ អនុប្រធានភូមិថ្មី ព្រោះថាសម័យវានៅសង្គ្រាមដូច្នេះ មេភូមិពេលនោះវែកអំវែកដល់ទៅ៤-៥ ណាអំវែក គ្រួសារ ណាវែកទាហានខាងនេះ ណាវែកខ្មែរក្រហម ណាវែកប៉ាវ៉ា ទូដងវែកដងបុកគ្នា ឡើងសាប់ ឡើងរស់ ។ ហើយខ្ញុំមិនដែលបានទៅដេកផ្ទះនេះទេ ត្រង់ណាដែលមានដុំអាចម៍ ត្រង់ណាដែលមានដុំខ្លាំង ខ្ញុំដេកត្រង់នោះ ព្រោះដេកក្នុងផ្ទះគេមករកនៅផ្ទះពួកខ្មែរក្រហម តែគេឃើញត្រង់ណា គេសម្លាប់ចោលត្រង់នោះ ។ ដល់ហើយដេកហាលភ្លៀងហាលផ្គរតែឯងទៅវេទនា កម្មណាស់ ទម្រាំបានស្រួលប៉ុននេះ ។

ធានី : ចឹងកាលពូធ្វើអនុភូមិនឹង ពូដឹងរឿងដែលប្រជាជនទៅព្រះនេត្រព្រះ ដែលថាគេខ្មែរក្រហមបាញ់សម្លាប់?

រស់ : បាទ! ដែលខ្មែរក្រហមសម្លាប់នៅត្រពាំងថ្មនោះ ខ្ញុំនេះឯង អ្នកបាត់តាំង ។

ធានី : ឆ្នាំប៉ុន្មានដែរ?

រស់ : អូ! ភ្លេចឆ្នាំ ។ ប្រហែលជា៨៨ ៨៩នេះឯង ។

ធានី : កាលនឹងម៉េច?

រស់ ៖ ទិសគេដាក់ពីលើមកដាក់គ្រប់តែស្រុក តែភូមិនោះឯង គេឲ្យបងប្អូនយើងនេះទៅដឹកបារ៉ែន ដើម្បីទាហានការពារក-៥ ដូចវរសេនាជន ។

ធានី ៖ ដឹកអីគេ?

រស់ ៖ ដឹកបារ៉ែនការពារ បារ៉ែនជុំវិញភូមិឲ្យប្រជាជនដឹក ទាហានការពារ ។

ធានី ៖ ចុះម៉េចបានទៅដឹកនៅត្រពាំងថ្មវិញ?

រស់ ៖ ព្រោះត្រពាំងថ្មនឹង អត់ទាន់បានដឹក ព្រោះកម្លាំងវាចល័តគ្នា ជួនកាលវត់ទៅដឹកនេះ ជួនកាលទៅដឹកនោះ យើងទៅដឹកគេ គេធ្វើដីយើង ទៅសំបើមដូចជាក-៥ វរៈសេនាជន ។

ធានី ៖ តែអានឹងមិនមែនក-៥ ទេ?

រស់ ៖ ទេ! អានោះមិនមែនក-៥ ទេ គេឲ្យទៅដឹកបារ៉ែនរួចយើងមកវិញ ។

ធានី ៖ បារ៉ែននឹងយ៉ាងម៉េច?

រស់ ៖ ដូចបន្ទាយទាហានៗ ។

ធានី ៖ ត្រង់សេរ?

រស់ ៖ យើងដឹកជុំវិញចេះ កន្លែងពួកនេះនៅជិតជុំវិញ ។

ធានី ៖ ដូចស្រះ?

រស់ ៖ បាទ! ទាហាននៅការពារយាម ។

ធានី ៖ ហើយប៉ុន្មាននាក់ភូមិយើងទៅ?

រស់ ៖ អឺ! កាលនោះទៅប៉ុន្មាននាក់ទេ ប៉ុនខ្ញុំឲ្យជល់មេភូមិ អឺ!ជល់តាវុនគេមេភូមិ ហើយខ្ញុំអនុមេភូមិ ជំនួសមេភូមិអីទាំងអស់ ខ្ញុំប្រើឲ្យតាឆាត់ទៅ ។ ប្រើតាឆាត់នាំបងប្អូនទៅ ។

ធានី ៖ ប៉ុន្មាននាក់?

រស់ ៖ ទៅកាលនោះទៅច្រើន ប្រហែល៤-១០-២០នាក់ ។

ធានី ៖ ថា២០នាក់?

រស់ ៖ បាទ! ថា២០នាក់ចុះៗ ដល់ទៅដល់ទៅ គេធ្វើរោងធ្វើអី មិនទាន់បានដឹកទេ ធ្វើរោងអាភូមិគេក៏ទៅ យើងក៏ទៅ ។ ជាពិសេសងាប់ច្រើនជាងគេ ប៉ោយព្រីង ប៉ោយសំរោង ដែលងាប់ច្រើន ។

ធានី ៖ ហេតុអី?

រស់ ៖ ខ្មែរក្រហមមកបាញ់ ។

ធានី ៖ ពេលកំពុងដឹកនឹង?

រស់ ៖ ទេ! អត់មានកំពុងដឹកទេ ទៅដល់អត់ទាន់បានដឹកទេ ទៅដល់ធ្វើរោងនៅក៏រួចថាដឹក ស្អែកឡើងដឹក ថ្ងៃមិនទាន់បានដឹកយើងធ្វើរោងសិន ។ ដល់ធ្វើរោងអីរួចទៅ ឈ្មោះតាសំឡីៗ ថាកុំដេកថ្ងៃនេះថ្ងៃមិនល្អទេ យើងចាំទៅដេកភូមិសិន ស្អែកចាំថ្ងៃល្អ ចាំយើងមកពីផ្ទះ ហើយយើងរកថ្ងៃល្អដេក នាំគ្នាទៅដេកភូមិ ។ ដល់ពួកព្រះនេត្រព្រះនេះ គេមិនបានដេកនៅ នោះទេ ដេកនៅរោង ។ ដល់ដេកនៅរោង ខ្មែរក្រហមមកដល់ក៏បាញ់គ្នាចេះចុះ ។ បាញ់គ្នា តតាំងមានអី ។

ធានី ៖ ចុះពូដូចថារដ្ឋយើងមានទៅជូនប្រជាជនឲ្យទៅវិញ ព្រោះកន្លែងនឹងកន្លែងគេច្បាំងគ្នា ម៉េចមិនព្រមឲ្យទាហានអ្នកទៅវិញ?

រស់ ៖ អត់មានកន្លែងច្បាំងគ្នាទេ អានោះគេឲ្យយើងទៅដឹក ដើម្បីការពារឲ្យទាហាននៅនោះ គេការពារកុំឲ្យខ្មែរក្រហមចូលស្រុក ចូលភូមិបាន មិនមែនសម្រាប់ទៅតតាំងគ្នាទេ ។

ធានី ៖ ឲ្យយើងប្រជាជនទៅដឹក?

រស់ ៖ ឲ្យទៅដឹកដូចចូលវរសេនាធនក-៥ ឲ្យប្រជាជនយើងអ្នកកាប់ដុបកាប់ព្រៃទៅ ទាហានគេនៅយាមខ្មាំង ឲ្យឃើញពីចំងាយ ។

ធានី ៖ ចឹងទាហានអ្នកមើលពីចំងាយ ហើយបានយើងអ្នកកាប់?

រស់ ៖ ទេ! ទាហាននៅជិតនឹងឯង ប៉ុនពេលដែលយើងកាប់ ឲ្យប្រជាជនយើងអ្នកកាប់ យប់ឡើងបានវាមក ។

ធានី ៖ ប៉ុន្តែ ប្រជាជននៅលាយជាមួយទាហាននឹងទៅ?

រស់ ៖ ទាហានគេនៅណា ទាហានមិនមានប៉ុន្មាន ទាហាននៅតិចតួច ក៏នៅបំរុងតតាំងទេ ថាប្រជាជនគេធ្វើបាប ក៏ទាហានគេមិនហ៊ាននៅ ។ ដល់យប់ឡើងបានគេបាញ់គ្នាទៅ របួសតិចតួច គេដុតរោងពីលើទៀត ខ្មែរក្រហម ។ ដុតរោង អាគ្នារបួសហើយឆេះរោងពីលើទៀត គេចទៅណារួច ងាប់ក្នុងភ្លើងនឹងហើយ ។ ងាប់អស់ច្រើនកាលនោះ ។

ធានី ៖ ចឹងបន្ទាប់មកម៉េចទៀត បន្ទាប់ពីពូធ្វើអនុភូមិហើយ ពូធ្វើអីទៀត?

រស់ ៖ ដល់ខ្ញុំធ្វើអនុភូមិនោះរួច ចប់សព្វគ្រប់ទៅ ដល់ពេលឆ្នាំ៨៥នេះ ខ្ញុំធ្វើឃុំនេះ ខាងវិភាគទាន ។

ធានី ៖ ឃុំអីគេ?

រស់ ៖ ឃុំព្រះនេត្រព្រះ ។

ធានី ៖ ពូធ្វើមេឃុំ ឬក៏?

រស់ : អត់ទេ ខ្ញុំខាងកូនចៅគេ នៅខាងវិភាគទាន កាលសម័យនោះវិភាគទាន ។

ធានី : ធ្វើសមាជិក?

រស់ : អត់ទេ សមាជិកក៏មិនមែន អីក៏មិនមាន អីគេដកពីនេះទៅ គេសម្រាប់នៅវិភាគទាន ។ វិភាគទាននោះបានន័យថា ពេលដែលវៀតណាមរំដោះបាន កាលនោះគេមិនទិញស្រូវ គេឲ្យមេភូមិនោះទិញស្រូវពីប្រជាជនម៉ាគីឡូ៧-៨កាក់ ។ ដូច្នេះ គេឲ្យបងប្អូនមកលក់ស្រូវ ហើយខ្ញុំសុំវិភាគទានពីគេ កាលនោះស្រូវប៉ុននេះប៉ុននោះ សុំវិភាគទានប៉ុន្មាន ២រៀល ឬ២-៣កាក់ ។

ធានី : តែពូវិភាគទាននឹង ឬក៏?

រស់ : អត់ទេ គ្មានប្រធានទេ ប្រធានគេនៅស្រុកនោះ ប៉ុន្ដែខ្ញុំគ្រាន់ជាកូនចៅអន្ទុយចាំប្រមូលស្រូវ ។

ធានី : តែនៅឃុំយើងនឹង?

រស់ : បាទ! ប៉ុនមិនមានប្រាក់ខែ មានរបបអីតិចទេ ។

ធានី : តែគេហៅអី អ្នកវិភាគទានចឹង?

រស់ : វិភាគទានៗឃុំ ។ បានឈប់វិភាគទាននោះទៅ ដល់ឈប់លក់ស្រូវ ខែវស្សាឡើងក៏ខ្ញុំធ្វើកសិកម្ម ។

ធានី : ធ្វើអីគេកសិកម្ម?

រស់ : កសិកម្ម ឧបមាថាដីស្រែ ដីព្រៃ ជួលត្រាក់ទ័ររដ្ឋទៅភ្ជួរទៅនេះទៅនោះ ។

ធានី : ប៉ុន្ដែនៅក្នុងវិភាគទាននឹងដែរ?

រស់ : អត់ទេ ។

ធានី : ផ្សេងទៀត?

រស់ : ដល់ខាងកសិកម្មនេះ មើលដី មើលជ្ជីឲ្យបងប្អូនប្រជាជន ។

ធានី : ចែកដីឲ្យគាត់នឹងម៉ែន?

រស់ : បាទ!

ធានី : គេហៅអីគេកន្លែងនឹង?

រស់ : គេហៅកសិកម្ម ។

ធានី : អត់ទេ ពេលនឹងមុខងាររបស់ពូ គេហៅអីគេ?

រស់ : មុខងារកសិកម្ម ។

ធានី ៖ តែសម្រាប់ភូមិនឹងដែរ?

រស់ ៖ បាទ! ប៉ុនមេឃុំ ។

ធានី ៖ គេដាក់មេឃុំ?

រស់ ៖ ទេ! មេឃុំគេផ្សេង ។

ធានី ៖ ចុះដាក់អី?

រស់ ៖ វាអត់មានជា នោះហើយធ្វើការនៅកន្លែងឃុំ ប៉ុនមានភារកិច្ចស្អីទេ ប៉ុនគេដាក់ទៅខាងកសិកម្ម ទៅខាងវិភាគទាន ។

ធានី ៖ ប៉ុន្តែពូមានផារបែក មើល ដី ធ្វើស្រូវ និងចែកដីសម្រាប់ប្រជាជនដែលមកភូមិនឹង?

រស់ ៖ បាទ! ដោះស្រាយដីដែលមានរឿងរ៉ាវអីនេះនោះ ។ ដល់ឈប់ពីនោះទៅ បានខ្ញុំនេះខាងសមាជិកក្រុមប្រឹក្សា ។

ធានី ៖ នៅឆ្នាំប៉ុន្មាន?

រស់ ៖ សមាជិកក្រុមប្រឹក្សានៅឆ្នាំ២០០២ ។

ធានី ៖ ចុះឥឡូវ?

រស់ ៖ សព្វថ្ងៃអត់ ។

ធានី ៖ ឥឡូវសម្រាកនៅផ្ទះ?

រស់ ៖ បាទ! សម្រាកនៅផ្ទះ ។

ធានី ៖ ធ្វើស្រែចំការដែរ?

រស់ ៖ ចំការចុះហើយ ធ្វើដូចជាមាត់ធ្វើចំការរួចម៉ាវ៉ៃ តិចតួចផ្សំ ធ្វើតែស្រែ ។

ធានី ៖ ធ្វើស្រែច្រើនដាង?

រស់ ៖ ស្រែខ្ញុំ ដីដែលគេចែកឲ្យដូចតែបងប្អូន ប៉ុនខ្ញុំបានទិញក្រៅ មិនទិញវាលនេះទេ ទៅទិញដល់វាលដូនឡឹក ដល់ទៅអី ទៅទិញបាននេះនោះបានសរុបទៅ២០ហិចតា ។ នេះ ដល់ខ្លួនចាស់ហើយក៏ដោះដូរលក់ចង់លក់ស្រែទៅវិញគ្រាន់ធ្វើបុណ្យធ្វើទាន ។

ធានី ៖ ចឹងគ្រួសារពូអត់មានកូនទេ?

រស់ ៖ អត់ ។

ធានី ៖ ចឹងមីងចាន់ ទី?

រស់ ៖ បាទ! គ្មានទេ(កូន) ។

ធានី ៖ ពូដែលដឹងរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

រស់ ៖ អត់ដឹងទេ លោកគ្រូ ព្រោះថាខ្ញុំក៏ ។

ធានី ៖ អត់ទេ ដែលពូថាមានតុលាការកាត់ទោសមេដឹកនាំ?

រស់ ៖ ពូដែរ ពូតាមរាជ្យ ប៉ុនថាឲ្យពូតាមនេះ វាមិនដែលបានទៅ គេហៅទៅកាត់ទោសកាត់អី ខ្ញុំក៏មិនដែលទៅឃើញទៅអីទេ ។

ធានី ៖ ប៉ុន្តែបានដឹងដែរ?

រស់ ៖ បានដឹងថានៅតាម ។

ធានី ៖ ពូចង់ទៅទេ?

រស់ ៖ បាទ! កាត់ទោសៗទៅហើយ ។ ចង់ដើរលេងហើយ ចង់ទៅកាត់ទោសកុំឲ្យប្រកែកបានពីសម័យកាលនោះ ដែលថាគាត់ធ្លាប់បានរស់ ធ្លាប់បានល្អឹងដូរចត់សម័យនោះ កុំហៅកែកុនទៅ ចេះទៅចុះបាន ។

ធានី ៖ ចឹងពូគិតថាតុលាការមានប្រយោជន៍អីអត់?

រស់ ៖ តុលាការមានប្រយោជន៍ ប៉ុនដល់ពេលកាត់ទោសស្រាប់ដឹងយ៉ាងណា ដឹងថាល្អៃយ៉ាងៗណា ។

ធានី ៖ ពូដឹងថាគេកាត់ទោសខុចហើយ មានដឹងរឿង?

រស់ ៖ កាត់ហើយ ប៉ុនគ្រាន់ថាទោសដែលសម្លាប់ច្រើន គួរណាស់ថាយើងសម្លាប់ចោលឲ្យអស់ដល់អាចេះក៏គាត់ទៅក៏ដូចជាមិនកាត់ដដែល នៅជាប់គុកអ្នកធំ ក៏ស្រួលជាងយើងអ្នកស្រែទៅទៀត ដេកតែពូក ដេកតែស្ពី ស៊ីម៉ាស្រឡាញ់ ហើយឈឺម៉ាតិចពេទ្យគេព្យាបាល មិនដឹងថាយ៉ាងណា ។

ធានី ៖ ដោយសារសម័យឥឡូវយើងមានសិទ្ធិមនុស្ស មានអីចឹង វាអត់ដូចសម័យខ្មែរអីចឹងគាត់មិនដែលបានដឹងសិទ្ធិមនុស្សយ៉ាងម៉េច ។ បើសិនជាយើងធ្វើដូចជាគាត់នៅសម័យនឹង មានតែយើងជាគាត់ដដែល ។ ចឹងយើងកាត់ទោសគាត់យ៉ាងម៉េចកើត បើសិនជាដូចថាកាលសម័យនឹង គាត់បង្អត់បាយយើង បើសិនជាយើងធ្វើឥឡូវគាត់អាយុច្រើនហើយ ។ បើគាត់អត់បាយមានអ្នកណាយកគាត់ទៅកាត់ទោសកើតទៀត ។ ហើយសម័យនឹងគាត់នឹងយើងខុសអី ដែលហៅមកកាត់ទោសចឹង អត់មានទេ អ្នកស្លាប់គឺស្លាប់ហើយ ។ ដូចគាត់និយាយចឹង ។

រស់ ៖ អត់មានទេ អត់មានកាត់ទោស ។

ធានី ៖ ដល់ពេលចឹងសម័យយើងឥឡូវត្រូវរកខុសរកត្រូវ ហើយដើម្បីក្មេងៗក្រោយឲ្យបានដឹងថា ទោះជាអ្នកនឹងធ្វើយូរមកហើយ ទោះជាគាត់ចាស់ក៏ដោយក៏ត្រូវយកគាត់មកកាត់ទោស ដើម្បីទុកឲ្យជាមេរៀនមួយទុកឲ្យក្មេងជំនាន់ក្រោយ ។ ហើយអ៊ីដែលសំខាន់ តុលាការរាល់ថ្ងៃ ថាមានពូក មានខ្នើយ មានអីៗហូបចុកនឹង គឺគេថែរក្សាសុខភាពគាត់ ដើម្បីឲ្យកាត់ទោសឲ្យរួច ព្រោះបើមិនចឹងទេ មិនទាន់បានកាត់ទោសផង គាត់ស្លាប់ទៅ យើងធ្វើម៉េចដឹងរឿង ។ ចុងក្រោយយើងអត់បានច្បាស់ទាំងអស់គ្នាដដែល ដូចអ្នកដែលស្លាប់នៅសម័យមុន ចឹង សម្លាប់ទៅអ្នកដែលស្លាប់នឹងគាត់អត់ដឹងថាគាត់មានកំហុសអីផងពេលខ្លះ ហើយបង ប្អូនក៏អត់ដឹងដែរ ។ ដល់ពេលឥឡូវនេះដែលយើងយកគាត់មកកាត់ទោសទាំងអស់នេះទៅ យើងដឹងទាំងអស់គ្នា មិនថាពូ មិនថាសាច់ញាតិគាត់ទេ យើងដឹងថាគាត់នឹងមានធ្វើអី ហេតុអីបានគាត់ត្រូវគេយកមកកាត់ទោសចឹង ។ ចឹងពូដឹងថាឌុចកាត់ទោសប៉ុន្មានឆ្នាំ?

រស់ ៖ ហ៊ឺ! ត្រង់នោះ ដូចអត់សូវបានដឹង ។

ធានី ៖ ចុះពូដឹងថាប៉ុន្មាននាក់ទៀត ដែលគេនឹងត្រូវយកមកកាត់ទោសបន្តទៀត?

រស់ ៖ ដល់ខានស្តាប់យូរក៏ភ្លេច ។

ធានី ៖ ឌុច គាត់ត្រូវបានគេកាត់ទោសហើយ ហើយគេចេញសាលក្រមកាលពីថ្ងៃ៣០ខែមិនា ក៏ប៉ុន្តែគេមានប្តឹងឧទ្ធរណ៍បន្តទៀត រហូតដល់ឥឡូវ ដោយសារតែគាត់អត់ពេញចិត្តនឹងការសម្រេចចិត្តរបស់តុលាការ ។ តែគេកាត់ទោស៣០ឆ្នាំ គេសំរួចចុះឡើងនៅសល់១៩ឆ្នាំ ។ ចឹងគេអត់ពេញចិត្ត គេប្តឹងត ។ ប៉ុន្តែរឿងរបស់ឌុច បន្ទាប់ពីប្តឹងឧទ្ធរណ៍ហើយ គឺចប់ហើយ គេហៅប្តឹងសារទុក្ខ ប្តឹងកំពូលនឹង ។ ប្តឹងលើកចុងក្រោយនឹងគឺចប់ ពេលដែលសាលក្រមចេញមកគឺអស់ហើយ ដែលខាងតុលាការនឹងចេញសេចក្តីសម្រេចចុងក្រោយ ។ នឹងចប់ឌុចហើយបញ្ជូនគាត់ទៅព្រៃសហើយ គាត់លែងបាននៅកន្លែងម៉ាស៊ីនត្រជាក់ទៀតហើយ ។ ដោយសារតែមុននឹង គាត់អត់ទាន់កាត់ទោសហើយ អត់ចេញសេចក្តីសម្រេចចុងក្រោយរបស់តុលាការ ចឹងគេអត់ទាន់យកទៅទេ ។ ដល់ពេលឥឡូវគេចេញហើយ គាត់នឹងត្រូវបញ្ជូនទៅព្រៃសវិញ គេឲ្យនៅដូចយើង ។

រស់ ៖ បាទ! កាត់ទោសចេះតែកាត់ហើយ ប៉ុន្តែអារឿងធ្វើបាប ធ្វើកំសត់ វាមិនគួរមាន ។

ធានី ៖ ចា៎! ត្រូវហើយពូ វាមិនអាចត្រឡប់មកវិញបានទេ រឿងរ៉ាវដែលពូឆ្លងកាត់វាលំបាកយ៉ាងម៉េច អ្នកផ្សេងយ៉ាងម៉េច ។

រស់ ៖ អានេះរឿងមួយត្រឹមត្រូវហើយ ដូចថាយើងមានកំហុសហើយ យើងមិនធ្វើបាបត្រឹមត្រូវហើយ ។ បើកាលណាធ្វើបាប យកពារទោសងពារក៏មិនចេះអស់ដែរ ។

ធានី ៖ សព្វថ្ងៃនេះ គេនឹងកាត់ទោសសម្រាប់ករណី០០២នឹង គេកាត់ទោសចំនួន៤នាក់ទៀត ដែលជាមេដឹកនាំជាន់ខ្ពស់នៅសម័យខ្មែរក្រហម មាននួន ជា, អៀង សារី, អៀង ធីរិទ្ធិ, ហើយនឹងខៀវ សំផន ។ ពូដែលឮឈ្មោះអ្នកទាំងអស់នឹង?

រស់ ៖ ឮកាលពេលសម័យដឹកនាំដែលខ្មែរក្រហមច្រូត មានខៀវសំផន មានអៀង សារី, ប៉ុល ពត ។

ធានី ៖ តាម៉ុក?

រស់ ៖ ទេ! តាម៉ុកទើបឮក្រោយសង្គ្រាម បើដឹកនាំប្រទេសកាលពីមុនឮតែ២-៣នាក់នឹងឯង ។

ធានី ៖ ដឹងពួកគាត់ជាអ្នកណា?

រស់ ៖ ទេ! ឮថាខៀវ សំផន គាត់ខាងរដ្ឋមន្ត្រីការពារប្រទេស ។

ធានី ៖ អត់ទេ គាត់ខាងប្រមុខរដ្ឋ?

រស់ ៖ ប្រមុខរដ្ឋ ។

ធានី ៖ គាត់នៅឆ្នាំ៧៦ គាត់ឡើងប្រមុខរដ្ឋបន្ទាប់ពីសម្តេច ។

រស់ ៖ ចុះអៀង សារី?

ធានី ៖ អៀង សារីបានក្រសួងការបរទេស ។

រស់ ៖ ចុះប៉ុល ពត?

ធានី ៖ ប៉ុល ពត ប្រធានធំ សម័យនឹងគេហៅនាយករដ្ឋមន្ត្រី ។

រស់ ៖ បាទ! នោះឯង ។

ធានី ៖ ហើយ ប៉ុល ពត គេអត់កាត់ទោសទេ ដោយសារគាត់ស្លាប់ហើយ ចឹងរឿងរ៉ាវអស់នឹង យើងអត់ដឹងដដែល ដោយសារគាត់ស្លាប់ អ្នកផ្សេងក៏ស្លាប់ យើងអត់ដឹងថាតើគាត់មានទោសអី ឬគាត់នឹងមានទោសអី យើងត្រូវចោទពីអីខ្លះ ក៏អត់មានដឹង ព្រោះគាត់អត់បាននៅរស់តទល់ជាមួយយើង ។ ចឹងយើងបានដឹងថាប៉ុលពតជាប្រធានធំនៅសម័យខ្មែរក្រហម ដោយសារតែអ្នកក្រោយ ខៀវ សំផន ជាប្រមុខរដ្ឋ, អៀង សារី គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេស, អៀង ធីរិទ្ធ គាត់ជាប្រពន្ធរបស់អៀងសារី ដែលជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចខាងថ្នាំពេទ្យខាងអី, ហើយមួយទៀត នួន ជា គាត់ជាប្រធានរដ្ឋសភា ។ អ្នកទាំង៤នឹងត្រូវគេយកមកកាត់ទោសនៅតុលាការ ។ ហើយចោទទាក់ទងនឹងបទល្មើសអន្តរជាតិច្រើន

ណាស់ ប៉ុន្តែវាសរុបសេចក្តីទៅ គឺទាក់ទងនឹងរឿងដែលគាត់ទាក់ទងនឹងបន្ទត់បាយ បន្ទុំឲ្យធ្វើ ការជាទំនន់ សម្លាប់មនុស្ស ដែលធ្វើឲ្យប្រជាជនខ្មែរស្លាប់ជាច្រើននាក់ ហើយបន្ទុំជម្លៀស គ្រប់បែបយ៉ាង ដូចពូត្រូវធ្វើការហត់ បំបែកចេញពីឪពុកម្តាយ ដូចថាអត់បាននៅជាមួយ គ្រួសារ អត់បាននៅជាមួយកូន ជាមួយម្តាយ ហើយទៅធ្វើការឆ្ងាយៗពីផ្ទះ បាក់កម្លាំង ហូបអត់គ្រប់គ្រាន់ ស្នាក់នៅអត់បានគ្រប់កន្លែង មានទឹកហូប ខោអាវស្លៀកពាក់ និយាយ ទៅទាក់ទងនឹងប្រជាជនយើងដែលអត់មានសេរីភាពគ្រប់បែបយ៉ាង ។ ហើយឥឡូវ គេចាប់ផ្តើមរៀបចំកាត់ទោសពួកគាត់ហើយ ។ ហើយពូយល់យ៉ាងម៉េចដែរ ចំពោះការកាត់ទោស នឹង?

រស់ : ទេ! កាត់ទោសនឹងមានយល់យ៉ាងម៉េច កាត់ទោសនឹងបើដូចខ្ញុំនិយាយពីខាងដើម បើថាយើងយកទោសកំហុសពួកនេះទៅធ្វើបាបយើង ទៅកាប់សម្លាប់គ្នាចោលក៏មិនបានផលប្រយោជន៍ ដល់កាត់ទោសបណ្តើរ ព្រោះថាដូចខ្ញុំថាចឹង យកពៀរទៅសងពៀរ វាមិនត្រឹម ត្រូវទេ ។ ពិចារណា បើសិនខបមាថាសម្លាប់ឪពុកគេ កូនគេក៏នៅមានការសងសឹក គេនៅ តែគេបើយើងយកអាពេលនេះទៅសងវិញនោះ ។ គាត់ធ្វើនេះត្រឹមត្រូវហើយ រដ្ឋាភិបាល ខ្ញុំមិនមានទំនាស់អីទេ ត្រឹមត្រូវហើយ កាត់ទោសនេះ ។

ធានី : ពូមានឈ្មោះអីដែរ?

រស់ : ឈ្មោះ ពេជ រស់ ។

ធានី : ឆ្នាំនឹងអាយុប៉ុន្មាន?

រស់ : ខ្ញុំ៥៦ ។

ធានី : ពូមានស្រុកកំណើតនៅណា?

រស់ : ស្រុកកំណើតនៅនេះឯង ។

ធានី : ស្រុកកំនើតនៅភូមិឃុំអី?

រស់ : ភូមិស្រះខាងកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបើនិយាយពីដើមមិញខេត្តបាត់ដំបងនោះ ប៉ុនដល់ខេត្តសព្វថ្ងៃ ខេត្តបន្ទាយមានជ័យ ។

ធានី : ឪពុកពូឈ្មោះអី?

រស់ : ឪពុកខ្ញុំឈ្មោះ ពេជ ធន់ ។ ប៉ុនគាត់ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណាដែរ?

រស់ ៖ ស្លាប់ដែលវៀតណាមចូល ។

ធានី ៖ វៀតណាមចូល៧៩?

រស់ ៖ ទេ! ខ្ទង់៨៥ ៨៦ ។

ធានី ៖ ៨៦ដោយសារអីដែរ?

រស់ ៖ គាត់មានជម្ងឺរោគា គាត់ចាស់ហើយ ។

ធានី ៖ ចុះម្ដាយពូឈ្មោះអីគេ?

រស់ ៖ ម្ដាយខ្ញុំឈ្មោះ គីម នួន ។ គាត់ស្លាប់ដែរ ។

ធានី ៖ ស្លាប់ពេលណា?

រស់ ៖ ស្លាប់ក្រោយឪពុកខ្ញុំ ។

ធានី ៖ ប៉ុន្មានឆ្នាំ?

រស់ ៖ ស្លាប់ប្រហែលជា៩៦ ៩៧ ។

ធានី ៖ ដោយសារអីដែរ?

រស់ ៖ ជម្ងឺរោគារបស់គាត់ ។

ធានី ៖ ពូមានបងប្អូនប៉ុន្មាននាក់?

រស់ ៖ ប្អូន៤នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

រស់ ៖ ស្រី១ ប្រុស៣ ។

ធានី ៖ គាត់នៅរស់ទាំងអស់ទេ?

រស់ ៖ ទេ! បងប្អូននោះស្លាប់មួយ នៅសល់៣ ។

ធានី ៖ ស្រីប្រុស ស្លាប់?

រស់ ៖ ស្លាប់ប្រុស ។

ធានី ៖ ដោយសារអីដែរ?

រស់ ៖ អានោះ ដោយសារទឹកនោមផ្អែម ។

ធានី ៖ ស្លាប់ឥឡូវទេ?

រស់ ៖ ស្លាប់២-៣-៤ឆ្នាំ ។

ធានី ៖ អា២០០៦?

រស់ ៖ បាទ! ប៉ុននោះឯង ដាក់២០០៥ នៅសល់បងប្អូន៣នាក់ ។

ធានី ៖ សព្វថ្ងៃពូអត់មានកូនទេ?

រស់ ៖ អត់ នៅតែកូនចិញ្ចឹម ។

ធានី ៖ មានកូនចិញ្ចឹមប៉ុន្មាននាក់?

រស់ ៖ កូនចិញ្ចឹមនេះមាន២ នៅនេះមួយ ក៏នៅដើងនោះមួយ ។

ធានី ៖ តែសុទ្ធតែក្មួយទាំងអស់?

រស់ ៖ ទេ! អាកូនចិញ្ចឹមនោះ អានោះស្រុកនៅបាត់ដំបង ដឹងថានៅណាទេ ។

ធានី ៖ ឈ្មោះអីគេ?

រស់ ៖ ឈ្មោះ អាតឿ បានប្រពន្ធហើយ កូន២-៣នាក់ ។

ធានី ៖ ហើយមួយទៀត?

រស់ ៖ មួយទៀតនេះ ឈ្មោះចាប ប្អូនកូនប្រពន្ធខ្ញុំបង្កើត ។ ។

ធានី ៖ ពូខ្ញុំអស់អីចង់សួរពូ ពូមានអីចង់សំណូមពរ ឬមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរ?

រស់ ៖ ទេ! គ្មានបន្ថែមអីទេ លោកគ្រូឆ្លើយអស់ទៅហើយ កាត់ទោសខ្មែរក្រហមអីផង ។

ធានី ៖ ពូមានលេខទូរស័ព្ទទេ?

រស់ ៖ ០៥៤ ៦៦៩ ៥៥១១ ខ្ញុំមិនដែលបានប្រើ ។

ធានី ៖ ចឹងអរគុណពូច្រើន ។

រស់ ៖ បាទ!

«ចប់»